សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## កិច្ចការស្រាវជ្រាវ

# កិច្ចសន្យាអាណត្តិ

កិច្ចការស្រាវជ្រាវពីថ្ងៃទី៣១ ខែ តុលា ឆ្នាំ២០១៤ ដល់ថ្ងៃទី១៤ ខែ វិច្ឆិកា ឆ្នាំ២០១៤

សាស្ត្រាចារ្យបង្រៀន

លោក **ជិន វណ្ណារ៉ា**

មុខវិជ្ជា **នីតិកាតព្វកិច្ច**


រៀបរៀងដោយ

និស្សិតឈ្មោះ លោក **ថាត ចាន់ថា**

កញ្ញា **គន្ធ គីមហេង**

លោក **យៀន ប៊ុនហាវ**

កញ្ញា **តឹក ចាន់មុន្នី**


**ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ**

**ឆ្នាំទី៣ ថ្នាក់ L3B1**

**ឆ្នាំចូលសិក្សា ២០១២**

**ឆ្នាំសិក្សា ២០១៣-២០១៤**

# អារម្ភកថា

## PREFACE

ក្រុមរបស់យើងខ្ញុំសែនមានសេចក្តីរីករាយជាពន្លឹក ដោយបានរៀបចំកិច្ចការស្រាវជ្រាវដែលទាក់ទងទៅនឹងកិច្ចសន្យា ដែលមានឈ្មោះថា *កិច្ចសន្យាអាណត្តិ* នេះឡើង កិច្ចការស្រាវជ្រាវមួយនេះគឺជាការខំប្រឹងប្រែងរបស់ក្រុមយើងខ្ញុំក្នុងការស្រាវជ្រាវ ហើយនឹងបានធ្វើការដកស្រង់នូវបទបញ្ញត្តិខ្លះៗដែលទាក់ទងទៅនឹងប្រធានបទចេញពីក្រមរដ្ឋប្បវេណីទាំងកម្ពុជា និង បរទេស ព្រមទាំងសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី និង សេចក្តីពន្យល់អំពីក្រមនីតិរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា និង ឯកសារផ្សេងៗទៀតដើម្បីគាំទ្រទៅលើកិច្ចការស្រាវជ្រាវមួយនេះ។ ការរៀបចំកិច្ចការស្រាវជ្រាវនេះ គឺធ្វើយ៉ាងណាឲ្យការស្រាវជ្រាវនេះ សមស្របទៅតាមកម្មវិធីសិក្សារបស់និស្សិតនៅថ្នាក់ឧត្តមសិក្សាក្រោយៗទៀត ហើយម្យ៉ាងទៀតបន្ទាប់ពីអ្នកសិក្សាបានសិក្សាចប់ អាចយកចំណេះដឹងដែលទាក់ទងទៅនឹងកិច្ចការស្រាវជ្រាវនេះ ទៅប្រើប្រាស់ក្នុងការសង្គម និង ប្រើប្រាស់នៅក្នុងជីវភាពរស់នៅឯកជនបាន។

កិច្ចការស្រាវជ្រាវនេះគឺជាទ្រឹស្តីដ៏មានសារៈសំខាន់មួយ ក្នុងការជួយអ្នកសិក្សា និង អ្នកស្រាវជ្រាវនានា អនុវត្តបានត្រឹមត្រូវទៅតាមគោលការណ៍នៃច្បាប់។ បច្ចុប្បន្ននេះប្រទេសទាំងឡាយនៅលើពិភពលោកយើងនេះ តែងតែខិតខំប្រឹងប្រែងធ្វើយ៉ាងណា ដើម្បីអភិវឌ្ឍប្រទេសជាតិខ្លួនឲ្យមានភាពរីកចម្រើនរុងរឿង និង ជឿនលឿន ហេតុដូច្នេះហើយដើម្បីឲ្យប្រទេសជាតិមានការរីកចម្រើន រុងរឿង និង ជឿនលឿនទៅបានចំបាច់ត្រូវពឹងផ្អែកទាំងស្រុងទៅលើវិស័យសេដ្ឋកិច្ចពាណិជ្ជកម្មជាស្នូល ដើម្បីឲ្យសេដ្ឋកិច្ច ពាណិជ្ជកម្មធ្វើប្រតិបត្តិការក្នុងវិសាលភាពដ៏ធំធេង និង ជាអន្តរជាតិទៅបានចំបាច់ត្រូវពឹងផ្អែកទៅលើវិធាននៃច្បាប់ពាក់ពន្ធ័ទាំងឡាយក្នុងនោះមានក្រមរដ្ឋប្បវេណី ច្បាប់ពាណិជ្ជកម្ម និង ច្បាប់កិច្ចសន្យា គឺជាច្បាប់មួយដែលត្រួតត្រា

គោលការណ៍ ផ្អែកតាមសេដ្ឋកិច្ចនៅលើពិភពលោក កិច្ចសន្យាគឺជាឧបករណ៍សម្រាប់តម្រង់ទិសដៅរាល់សកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម សកម្មភាពរបស់រដ្ឋាភិបាល និង ផ្នែកឯកជននៅក្នុងសង្គមទីផ្សារសេរី។ ជាថ្មីម្តងទៀត ក្រុមយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ទុកជាមុនជូនចំពោះអ្នកសិក្សា អ្នកអាន និង អ្នកស្រាវជ្រាវនានា សូមទទួលបាននូវចំណេះដឹងនេះ ឲ្យបានល្អប្រសើរធ្វើប្រតិបត្តិការប្រកបដោយប្រសិទ្ធិភាព និង ទទួលបាននូវសេចក្តីសុខសេចក្តីច្រើន រកស៊ីមានបានគ្រប់ៗគ្នាកុំបីខានឡើយ។

ក្រុមយើងខ្ញុំសង្ឃឹម និង ជឿជាក់ថានៅក្នុងការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំនេះ ទោះបីជាមានការខិតខំ ព្យាយាមពិនិត្យផ្ទៀងផ្ទាត់យ៉ាងណាក៏ដោយក៏នៅតែមានភ្លាំងភ្លាត់ខុសឆ្គងខ្លះៗ ដោយអចេតនាពុំខាន។ បើដូច្នេះខ្ញុំសូមអភ័យទោសអំពី សំណាក់អស់លោកមិត្ត អ្នកអានទុកជាមុននូវរាលកំហុសឆ្គងទាំង ឡាយដែលអាចកើតមានដោយ ចេតនាក្តី អចេតនាក្តី សូមខន្តីអរភ័យទោសដោយការគោរពយ៉ាង ស្មោះស្មគ្រ័ពីសំណាក់ក្រុមរបស់យើងខ្ញុំ ហើយក៏ទទួលស្វាគមន៍ នូវរាល់ការរិះគន់បែបស្ថាបនា ដើម្បីកែលំអព្រមទាំងបន្ថែមនូវគំនិតល្អៗដើម្បីបន្សល់ទុកឲ្យកូនខ្មែរជំនាន់ក្រោយក្នុងការសិក្សា។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៥

# សេចក្ដីថ្លែងអំណរគុណ

**ACKNOWLEDGEMENTS**

ក្នុងនាមក្រុមរបស់យើងខ្ញុំជា ក្រុមនិស្សិតស្រាវជ្រាវ ថ្នាក់បរិញ្ញាបត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្រ ដែលមានរាយនាមដូចខាងក្រោមៈ

១- លោក ថាត ចាន់ថា

២- លោក យៀន ប៊ុនហារ

៣- កញ្ញា គន្ធ គីមហេង

៤- កញ្ញា តឹក ចាន់មុន្នី

## សូមគោរពប្រតិបត្តិដោយសេចក្ដីកត្តញ្ញូតាធម៌ចំពោះ

❖ លោកអ្នកជា មាតាបិតាដែលបានផ្ដល់កំណើត និង ការចិញ្ចឹមបីបាច់ថែរក្សាអប់រំទូន្មានប្រៀនប្រដៅ និងការឧបត្ថម្ភទំនុកបំរុងគ្រប់បែបយ៉ាងដល់ការរស់រានមានជីវិត ដោយលោកទាំងពីរខិតខំពុះពារគ្រប់ឧបសគ្គមិនខ្លាចនឿយហាត់ និងព្រមទាំងជួយទំនុកបំរុង ដល់ការសិក្សារៀនសូត្រឲ្យយើងខ្ញុំបានសិក្សាក្រេបយកចំនេះដឹង និងក្លាយជាពលរដ្ឋល្អក្នុងសង្គមថ្ងៃនេះ។

❖ មិត្តរួមក្រុមរបស់យើងខ្ញុំដែល បានចំណាយពេល វេលាដ៏មាន តម្លៃធ្វើការស្រាវជ្រាវយ៉ាងម៉ត់ចត់ទៅលើប្រធានបទនេះ ហើយចេះសហការគ្នាធ្វើការស្រាវជ្រាវ យ៉ាងជិតស្និតដោយមិនគិតពីការនឿយហាត់ដោយបញ្ចេញមតិយោបល់យ៉ាងច្រើនទើបសម្រេចបានជាកម្រងឯកសារមួយនេះ។

❖ ឯកឧត្ដម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈកម្មការ និង សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំដឹកនាំ និងគ្រប់គ្រងក្នុងគោលបំណងបណ្ដុះ បណ្ដាលធនធានមនុស្ស ដើម្បីជាសសរទ្រូងប្រទេស។

❖ សាស្ត្រាចារ្យ **ខិន វណ្ណារ៉ា** ដែលជាសាស្ត្រាចារ្យទទួលបន្ទុកបង្រៀនមុខវិជ្ជា នីតិកាតព្វកិច្ច ដែលបានយកចិត្តទុកដាក់ក្នុងការបង្ហាត់បង្រៀន ជួយលើកទឹកចិត្ត ត្រួសត្រាយផ្លូវ និង ផ្ដល់នូវដំបូន្មានល្អៗទៅកាន់សិស្សនិស្សិតទូទៅ។

❖ លើសពីនេះ សូមអរគុណដោយស្មោះស្ម័គ្រ និង មោទនភាពជាតិបំផុតចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខដឹកនាំដែលបាននឹងកំពុងដឹកនាំនាវាកម្ពុជាលើផ្លូវនយោបាយ ដ៏ត្រឹមត្រូវមួយប្រកបដោយសុច្ចរិតភាព រក្សាបាននូវសុខសន្តិភាព ស្ថេរភាព និង ការអភិវឌ្ឍន៍ ហើយដែលជាការផ្តល់ឱកាសយ៉ាងប្រសើរ សំរាប់ការសិក្សា និង ការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំនាពេលនេះ។

ជាទីបញ្ចប់ សូមប្រសិទ្ធិពរជ័យ សិរីសួរស្តី វិបុលសុខ បវរមហាប្រសើរដល់លោកអ្នកមានគុណទាំងអស់ទទួលបានជោគជ័យគ្រប់ភារកិច្ច និង សុខភាពរឹងមាំទទួលទានគ្រប់ៗគ្នាព្រមទាំងពុទ្ធពរទាំងប្រាំប្រការទៀតគឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

# សេចក្ដីផ្ដើម

## INTRODUCTION

កាតព្វកិច្ច គឺជាទំនាក់ទំនងគតិយុត្តដែលចង់បុគ្គលពីរនាក់ដោយអោយបុគ្គលម្នាក់មានករណីយកិច្ចមួយចំនួនចំពោះបុគ្គលម្នាក់ទៀត ហើយកាតព្វកិច្ចនេះកើតចេញពីប្រភពពីរយ៉ាងគឺៈកាតព្វ កិច្ចកើតចេញពីឆន្ទៈរបស់គូរភាគី និង កាតព្វកិច្ចកើតពី ការកំណត់ដោយច្បាប់។ ក្នុងដំណាក់កាលអនុវត្តកិច្ចសន្យា ភាគីទាំងសងខាងត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនរៀងៗខ្លួនដោយសុចរិត និង ស្មោះត្រង់ស្របតាមខ្លឹមសារនៃកិច្ចសន្យា ហើយកាលណាគូរភាគីបានបំពេញកាតព្វកិច្ចចប់សព្វគ្រប់នោះធ្វើអោយកាតព្វកិច្ចត្រូវបានរលត់។ ហើយកិច្ចសន្យាក៏ជាកាតព្វកិច្ចចំបងមួយ ដែលមានសំខាន់បំផុតក្នុងការប្រើប្រាស់ក្នុងវិស័យពាណិជ្ជកម្ម ជំនួញ និងសម្រាប់ប្រើប្រាស់ក្នុង ជីវភាពរស់នៅប្រចាំថ្ងៃនៅ ក្នុងសង្គមរបស់ប្រជាពលរដ្ឋម្នាក់ៗ។ ហើយយើងសង្កេតឃើញថាត្រង់ចំណុចនេះ ច្បាប់កិច្ចសន្យាបានត្រួតត្រាលើគោលការណ៍ផ្នែកសេដ្ឋកិច្ចនៅលើពិភពលោក វាជាឧបករណ៍សម្រាប់តម្រង់ទិសរាល់សកម្មភាពពាណិជ្ជកម្ម សកម្មភាពរបស់រដ្ឋាភិបាល និង ផ្នែកឯកជនផងដែរ។

ច្បាប់កិច្ចសន្យានេះ ជានយោបាយមូលដ្ឋាននៅក្នុងសង្គមប្រកាន់លទ្ធិប្រជាធិបតេយ្យអនុវត្តគោលនយោបាយសេដ្ឋកិច្ចទីផ្សារសេរី ព្រោះថាសង្គមបែបនេះលើកស្ទួយការបំពេញកាតព្វកិច្ច និង ការប្រតិបត្តិកិច្ចសន្យានានា ក្នុងគោលបំណងធ្វើយ៉ាងណាជួយដល់អ្នកវិនិយោគទុន សហគ្រាសអាជីវកម្មនានា រួមទាំងអាជីវកម្មសម្រាប់គ្រួសារតូចតាច សាជីវកម្មពហុជាតិសាសន៍ធំៗ ក្នុងការទិញលក់ ទំនិញ វត្ថុធាតុដើម សម្ភារៈផ្គត់ផ្គង់ និងសេវាកម្មផ្សេងៗទៀត។ នៅលើលោកនេះគ្មានអាជីវកម្មណាមួយ បុគ្គលណាម្នាក់ មិនប្រើប្រាស់កិច្ចសន្យានោះទេ ហើយដើម្បីឲ្យការធ្វើកិច្ចសន្យាបញ្ចៀសបាននូវហានិភ័យនានា និង អសុពលភាពក្នុងការអនុវត្តកិច្ចសន្យា យើងត្រូវតែសិក្សាអំពីច្បាប់កិច្ចសន្យាឲ្យបានស៊ីជម្រៅ និង ច្បាស់លាស់។

ហើយអ្វីដែលជាចំណុចដ៏សំខាន់ក្នុងច្បាប់កិច្ចសន្យានោះគឺ កិច្ចសន្យាអាណត្តិដែលជាកិច្ចសន្យាមួយដែលប្រជាពលរដ្ឋតែងតែប្រើប្រាស់ និង ជួបប្រទះក្នុងជីវភាពប្រចាំថ្ងៃ ហើយវាក៏មានសារៈសំខាន់ផងដែរ ព្រោះថាកិច្ចសន្យាអាណត្តិក៏មានចែងនៅក្នុងក្រមរដ្ឋប្បវេណីមិនថាកម្ពុជា ឬ បរទេសនោះទេ។ កិច្ចសន្យាអាណត្តិ បើយោងតាមមាត្រា៦៣៧ នៃក្រមរដ្ឋប្បវេណីអាណត្តិសំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាងហៅថាអាណត្តិទាយកប្រគល់សិទ្ធិអំណាចឲ្យភាគីម្ខាងទៀត ហៅថាអាណត្តិគាហក ធ្វើការចាត់ចែងកិច្ចការ ដើម្បីអាណត្តិទាយក។ ដោយឡែកមាត្រា១២៦៨ នៃក្រមរដ្ឋប្បវេណីចាស់កំណត់ថាកិច្ចសន្យាអាណត្តិគឺជាកិច្ចសន្យាទាំងឡាយណាដែលជនម្នាក់ឲ្យអំណាចទៅជនម្នាក់ទៀតឲ្យយកទៅបំពេញកិច្ចខ្លះខាងតុលាការក្នុងនាមខ្លួន និង តាងខ្លួន។ លើសពីនេះទៀតមាត្រា៣៦៤ នៃក្រមរដ្ឋប្បវេណីថ្មីកំណត់ការតំណាងមានចរិកលក្ខណៈផ្សេងពីអាណត្តិ។ ការតំណាងសំដៅទៅលើទំនាក់ទំនងគតិយុត្តដែលមានអានុភាពនៃកិច្ចសន្យាត្រូវមាន ចំពោះម្ចាស់សិទ្ធិផ្ទាល់ក្នុងករណីដែលអ្នកតំណាងធ្វើកិច្ចសន្យាជាមួយភាគីម្ខាងទៀតដោយបង្ហាញថាការធ្វើកិច្ចសន្យានោះគឺធ្វើសម្រាប់ម្ចាស់សិទ្ធិក្នុងទំហំនៃសិទ្ធិតំណាង។ បើយើងក្រឡេកមើលទៅលើក្រមរដ្ឋប្បវេណី នៃបណ្តាប្រទេសនានា មានប្រទេសជាច្រើនដែល បានរៀបចំបញ្ញត្តិស្តីពីអាណត្តិនៅក្នុងក្រមរដ្ឋប្បវេណី។ ឧទាហរណ៍ មាត្រា៦៤៣ ដល់មាត្រា៥៦៤ នៃក្រមរដ្ឋប្បវេណីជប៉ុន មាត្រា១៩៨៤ ដល់មាត្រា២០១០ នៃក្រមរដ្ឋប្បវេណីបារាំង។ ប៉ុន្តែក្រមរដ្ឋប្បណីនៃប្រទេសមួយចំនួនបញ្ញត្តិស្តីពីអាណត្តិរាប់បញ្ចូលផងនូវបញ្ញត្តិស្តីពីប្រពន្ធ័ដែលមានលក្ខណៈ ស្រដៀងគ្នានឹងអាណត្តិដូចជាការតំណាង (ការតំណាងដែលច្បាប់កំណត់) ជាដើម។

ក្នុងចំណោមក្រមរដ្ឋប្បវេណីរបស់បណ្តាប្រទេសនានា បញ្ញត្តិស្តីពីអាណត្តិត្រូវបានរៀបចំឡើង ដោយយកក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ក្រមរដ្ឋប្បវេណីជប៉ុន និង ក្រមរដ្ឋប្បវេណីបារាំងជាអាទិ៍ មកធ្វើជាមូលដ្ឋានចម្បង។

# មាតិកា

**CONTENTS**

**អារម្ភកថា**....................i

**សេចក្ដីថ្លែងអំណរគុណ**....................ii

**សេចក្ដីផ្ដើម**....................iii

**មាតិកា**....................v

**១. សញ្ញាណទូទៅនៃកិច្ចសន្យាអាណត្តិ**

១.១ និយមន័យ....................១

១.២ លក្ខខណ្ឌបង្កើតកិច្ចសន្យាអាណត្តិ....................៣

**២. អានុភាពនៃកិច្ចសន្យាអាណត្តិ**

២.១ករណីកិច្ចរបស់អាណត្តិគាហក....................៣

២.២ ករណីកិច្ចរបស់អាណត្តិទាយក....................៦

**៣. ការបញ្ចប់កិច្ចសន្យាអាណត្តិ**

៣.១ ការរំលាយកិច្ចសន្យាអាណត្តិ....................៩

៣.២ អានុភាពនៃការរំលាយ....................៩

៣.៣ មូលហេតុនៃការបញ្ចប់កិច្ចសន្យាអាណត្តិ....................១០

៣.៤ លក្ខខណ្ឌតតាំងនៃការបញ្ចប់អាណត្តិ....................១១

**សេចក្ដីសន្និដ្ឋាន**

**ឧបសម្ព័ន្ធ**

**ឯកសារយោង**

# កិច្ចសន្យាអាណត្តិ

**(Contract of Mandate)**

## ១. សញ្ញាណទូទៅនៃកិច្ចសន្យាអាណត្តិ

ភាពចាំបាច់នៃរបបតំណាង មិនមែនត្រឹមតែសម្រាប់ការពារជនដែលត្រូវកម្រិតសមត្ថភាពដោយផ្អែកលើរបបតំណាងដែលច្បាប់បានកំណត់តែប៉ុណ្ណោះទេ។ ជាធម្មតាសកម្មភាពទាំងឡាយដែលមនុស្សនៅក្នុងសង្គមអាចធ្វើបាន គឺមានកម្រិតព្រំដែនកំណត់។ ឧទាហរណ៍គេមិនអាចធ្វើជំនាញនៅអូសាកាផង និង នៅតូក្យូផងក្នុងពេលតែមួយបាននោះទេ។ ហេតុដូច្នេះប្រសិនបើប្រើប្រាស់របបតំណាងទៅគឺគេអាចពង្រីកទំហំនៃសកម្មភាពជំនួញបែបនេះបាន។ ក្នុងករណីបែបនេះ អ្នកតំណាងត្រូវបានកំណត់ទៅតាមឆន្ទៈរបស់ម្ចាស់សិទ្ធិដែលគិតថាចង់ប្រើប្រាស់ជារបបតំណាង។ ដូច្នេះក្នុងន័យធៀបជាមួយការតំណាងដែលច្បាប់កំណត់ ការតំណាងប្រភេទនេះគេ ហៅថា ការតំណាងដោយអាណត្តិ។ ដើម្បីឲ្យអ្នកដទៃធ្វើជាតំណាង ដោយអាណត្តិបានមធ្យោបាយសាមញ្ញដែលត្រូវបានប្រើប្រាស់ គឺកិច្ចសន្យាអាណត្តិ[1] (ត្រូវបានប្រើប្រាស់ក្នុងទម្រង់ជាលិខិតប្រគល់អាណត្តិ) ដែលជាកិច្ចសន្យាមួយក្នុងចំណោមកិច្ចសន្យាជាច្រើនទៀតដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

### ១.១ និយមន័យ

ពាក្យ អាណត្តិ គឺជាកិច្ចសន្យាដែលជនម្នាក់ឲ្យអំណាចទៅជនម្នាក់ទៀត ឲ្យយកទៅបំពេញកិច្ចខ្លះ ខាងតុលាការក្នុងនាមខ្លួន ឬ តាងនាមឲ្យខ្លួន[2]។ ប៉ុន្តែឃ្លាថា «ក្នុងនាមខ្លួន» និង «តាងខ្លួន» ដែលបានប្រើនៅក្នុងមាត្រា ១២៦៨ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ត្រូវបានលុបចោល ។ មូលហេតុដោយសារតែមានការទិតៀនពីអ្នកច្បាប់កម្ពុជាថា មិនដឹងជាឃ្លានេះចង់សំដៅទៅលើអ្នកណាឲ្យប្រាកដ។ លើសពីនេះទៅទៀត មាត្រានេះមិនបានបញ្ជាក់ឲ្យបានច្បាស់លាស់អំពីទម្រង់នៃសកម្មភាពរបស់អាណត្តិគាហកថា តើធ្វើក្នុងនាមអណត្តិគាហក ឬ ក្នុងនាមអាណត្តិទាយកទេ។ ដូច្នេះ

[1] សេចក្តីផ្តើមនីតិរដ្ឋប្បវេណី និពន្ធដោយ លោកសាស្ត្រាចារ្យ ណូមឺរ៉ា តូយ៉ូហ៊ីរ៉ូ ឆ្នាំ២០១៤

[2] មាត្រា១២៦៨ នៃក្រមរដ្ឋប្បវេណីសង្គមចាស់ ឆ្នាំ១៩៦៧

ទើបក្រមរដ្ឋប្បវេណី ២០០៧ ត្រង់មាត្រា ៦៣៧ បានឲ្យនិយមន័យផ្សេង និង មានភាពច្បាស់លាស់ជាង ។

អាណត្តិ សំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាងហៅថា អាណត្តិទាយក ប្រគល់សិទ្ធិអំណាចឲ្យភាគីម្ខាងទៀត ហៅថា អាណត្តិគាហក ធ្វើការចាត់ចែងកិច្ចការដើម្បីអាណត្តិទាយក[3]។ មានន័យថា គឺជាការប្រគល់សិទ្ធរបស់អាណត្តិទាយក ទៅឲ្យបុគ្គលម្នាក់ទៀត ដែលនៅក្នុងក្រមរដ្ឋប្បវេណី ឲ្យឈ្មោះថា អាណត្តិគាហក ដើម្បីធ្វើនូវកិច្ចការទាំងឡាយក្នុងនាមម្ចាស់សិទ្ធិដែលជាអាណត្តិទាយកនោះ។

បើយើងធ្វើការវិភាគតាមក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុនវិញនោះ ខ្លឹមសារនៃកិច្ចសន្យាអាណត្តិ ជាសកម្មភាពទាំងឡាយណា ដែលជាសកម្មភាពគតិយុត្តដែលម្ចាស់សិទ្ធិអំណាចឲ្យអ្នកដទៃណាម្នាក់ ដើម្បីធ្វើសកម្មភាពតាមផ្លូវច្បាប់ក្នុងនាមខ្លួន ឬជំនួសឲ្យខ្លួន ដែលជាម្ចាស់លើសិទ្ធិនេះ ហៅថា **កិច្ចសន្យាអាណត្តិ** ។ ហើយសកម្មភាពដែលម្ចាស់សិទ្ធិបានប្រគល់សិទ្ធិអំណាចឲ្យនេះ មិនមែនមានតែសកម្មភាពតែគតិយុត្តិតែមួយនោះទេ តែក៏អាចមាននូវសកម្មភាពទាំងឡាយផ្សេងទៀត ក្រៅពីសកម្មភាពគតិយុត្ត ហៅថា **ឧបអាណត្តិ**។ ប៉ុន្តែនៅក្នុងខ្លឹមសារនៃកិច្ចសន្យាអាណត្តិខាងលើនេះ មិនកម្រិតត្រឹមសកម្មភាពគតិយុត្តតែម្យ៉ាងនោះទេ តែរាប់បញ្ចូលយ៉ាងទូលំទូលាយនូវការចាត់ចែងសំរាប់កិច្ចការទាំងឡាយផងដែរ។

ជារួមកិច្ចសន្យាអាណត្តិ គឺមានខ្លឹមសារដែលផ្តោតសំខាន់ទៅលើ ការប្រគល់សិទ្ធិអំណាចរបស់ខ្លួនទៅឲ្យបុគ្គលដទៃទៀត ដើម្បីធ្វើកិច្ចការជំនួសខ្លួន ហើយកិច្ចសន្យាដែលបានប្រគល់នេះ គឺមានកិច្ចការដែលជាសកម្មភាពគតិយុត្ត និង សកម្មភាពដទៃទៀត មិនមែនជាសកម្មភាពគតិយុត្ត។

ឧទាហរណ៍៖ លោក ក ប្រគល់សិទ្ធិលក់អចនវត្ថុឲ្យទៅលោក ខ។

ការប្រគល់សិទ្ធិឲ្យទៅមេធាវីធ្វើសកម្មភាពបណ្តឹង។

ទំនាក់ទំនងកិច្ចសន្យាព្យាបាលជំងឺរវាងគ្រូពេទ្យ និង អ្នកជំងឺ[4]។

---

[3] មាត្រា៦៣៧ នៃក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៧

[4] សេចក្តីកំណត់ក្រមចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៣ គន្ថីទី៥ មាត្រា៦៣៧ ទំព័រ ៨៥

### ១.២ លក្ខខណ្ឌបង្កើតកិច្ចសន្យាអាណត្តិ

កិច្ចសន្យាអាណត្តិត្រូវ បង្កើតឡើងដោយ ការព្រមព្រៀងរវាងភាគីទាំងពីរតែប៉ុណ្ណោះ[5] មានន័យថា ជាកិច្ចសន្យាដែលត្រូវបានបង្កើតឡើងដោយមានឆន្ទៈត្រូវគ្នារវាងម្ចាស់សិទ្ធិ និង អ្នកតំណាង។ ហើយមិនតម្រូវឲ្យមានលិខិតជាលាយលក្ខ័អក្សរ ជាលក្ខខណ្ឌ ដើម្បីបង្កើតអនុភាពនោះទេ ប៉ុន្តែក្រមរដ្ឋប្បវេណីចាស់តម្រូវឲ្យមានសរសេរជាលាយលក្ខ័អក្សរ។ ចំណែកនៅក្នុងក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុន និង ក្រមរដ្ឋប្បវេណីរបស់បារាំងវិញ ការបង្កើតកិច្ចសន្យាអាណត្តិនេះ ទោះបីជាធ្វើដោយផ្ទាល់មាត់ក៏ដោយ ក៏កិច្ចសន្យានេះមានសុពលភាពតាមផ្លូវច្បាប់ដែរ តែតម្រូវឲ្យមាននូវការបញ្ជាក់ពីសាក្សីផងដែរ ទើបមានសុពលភាពដើម្បីអនុវត្តន៍។

## ២. អានុភាពនៃកិច្ចសន្យាអាណត្តិ

ដូចគ្នា និង កិច្ចសន្យាដទៃទៀតដែរ កិច្ចសន្យាអាណត្តិនៅពេលដែលបង្កើតវា វានឹងមានអនុភាព។ នៅក្នុងកិច្ចសន្យាអាមញ្ញ ភាគីទាំងសងខាង គឺមានកាតព្វកិច្ចបំពេញករណីកិច្ចរវាងម្ចាស់បំណុល និង កូនបំណុល ចំណែកកិច្ចសន្យាអាណត្តិក៏ក្នុងករណីរបស់អាណត្តិគាហក និង ករណីកិច្ចរបស់អាណត្តិទាយកផងដែរ ។

### ២.១ ករណីកិច្ចរបស់អាណត្តិគាហក

ករណីកិច្ចប្រុងប្រយ័ត្ន អាណត្តិគាហកត្រូវទទួលនូវករណីកិច្ចប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្របគ្រងសុចរិត ដោយផ្អែកតាមអត្ថន័យនៃអាណត្តិ[6]។ ការប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងសុចរិត មានន័យថា ករណីកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហកជាករណីកិច្ចធ្ងន់ធ្ងរ។ ហេតុផលនេះ គឺដោយសារតែកិច្ចសន្យាអាណត្តិកើតឡើងដោយការទុកចិត្តគ្នានិងគ្នា។ អាណត្តិគាហក ត្រូវបំពេញករណីកិច្ចប្រុងប្រយ័ត្នក្នុងកម្រិតដែលជាទូទៅ អាណត្តិគាហកត្រូវបានតម្រូវឲ្យមាន ទៅតាមវិជ្ជាជីវៈដែលអាណត្តិគាហកធ្វើ ឋានៈផ្នែកសង្គម និង ផ្នែកសេដ្ឋកិច្ចរបស់អាណត្តិគាហកនោះ។ ទោះជាយ៉ាងណា ករណីកិច្ចរបស់អាណត្តិគាហក អាចត្រូវបានបន្ធូរបន្ថយតាមការព្រមព្រៀងរវាង

---

[5] មាត្រា ៦៣៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[6] មាត្រា ៦៤០ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ភាគី។ ឧទាហរណ៍ នៅក្នុងករណីនៃអាណត្តិដោយមិនយកកម្រៃ ករណីកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហកនឹងត្រូវបានបន្ធូរបន្ថយ។

ប្រសិនជាបើអាណត្តិគាហកបង្កឲ្យ មានការខូចខាតដល់អាណត្តិទាយកដោយសារការបំពានករណីកិច្ចប្រុងប្រយ័ត្ន អាណត្តិគាហកត្រូវទទួលខុសត្រូវក្នុងការសងសំណាងការខូចខាតទៅអាណត្តិទាយកនោះ។ នៅក្នុងករណីនេះ ប្រសិនជា អាណត្តិដោយមិនយកកម្រៃ តុលាការអាចបន្ថយចំនួនទឹកប្រាក់សំណងការខូចខាត។

ជាគោលការណ៍រាល់ ការខូចខាតដែលបានបង្កើត ឡើងទោះបីជនដែលបង្កនោះមានចេតនា ឬ គ្មានចេតនាក៏ដោយ គឺត្រូវជុសជុលនូវសំណាងការខូចខាតដែលខ្លួនបានបង្កឡើង ចំណែកបុគ្គលដែលទទួលរងនូវការខូចខាត មានសិទ្ធិទាមទារសំណាងនៃការខូចខាតបាន។ ចំពោះមាត្រានេះ ក្នុងករណីដែលអាណត្តិគាហក បានបំពានទៅលើកាតព្វកិច្ចប្រុងប្រយត្ន័ដោយសារកំហុសនេះ ហើយបានបង្កឲ្យមាននូវការខូចខាតកើតឡើងឲ្យដល់អាណត្តិទាយក អាណត្តិទាយកមានសិទ្ធិទាមទារសំណាងនៃការខូចខាតនោះពីអាណត្តិគាហកនោះវិញបាន ដោយយោងតាមគោលការណ៍ទូទៅអំពី ការមិនអនុវត្តន៍កាតព្វកិច្ច និង អំពើអនីត្យានុកូលភាព ។

ឧទារហណ៍ កញ្ញា សំណាងលាភ បានប្រគល់សិទ្ធិឲ្យកញ្ញា ឈានឈាន លក់ camera canon ដែលកញ្ញាបានទិញនូវតំលៃ 2000 ដុល្លារអាមេរិក។ នៅពេលដែលកញ្ញាឈានឈាន យកវាទៅលក់ស្រាប់តែកញ្ញាបានរអិលដៃធ្វើឲ្យធ្លាក់បែកអេក្រង់ camera។ ឃើញថាការខូចខាត camera នេះ គឺបណ្តាលមកពីការធ្វេសប្រហែស ខ្វះនូវការប្រុងប្រយត្ន័របស់កញ្ញា ឈានឈាន ដែលបណ្តាលឲ្យ camera នោះបានធ្លាក់បែកអេក្រង់។

ជាមួយនឹងសិទ្ធិទាមទារសំណាងនៃការខូចខាតរបស់អាណត្តិទាយកនេះ ករណីដែលកិច្ចសន្យាអាណត្តិ ដោយមិនយកប្រាក់កម្រៃ ទោះបីជាអាណត្តិគាហកបានបំពានលើកាតព្វកិច្ចប្រុងប្រយត្ន័ ហើយបណ្តាលឲ្យមានការខូចខាតក៏ដោយ ក៏តុលាការអាចបន្ធូរបន្ថយនូវចំនួនទឹកប្រាក់សំណាងនៃការខូចខាតបាន ចំពោះកិច្ចសន្យាអាណត្តិមិនយកកម្រៃនេះ។ ព្រោះបញ្ញត្តិនៃមាត្រានេះ អាចចែងពីភាពខុសគ្នារវាងអាណត្តិគាហក

ដែលយកកម្រៃ និង អាណត្តិគាហកដែលមិនយកកម្រៃ (បំពេញករណីកិច្ចដោយមិនយកកម្រៃ)។

ករណីកិច្ចរាយការណ៍ បើមានការទាមទាររបស់អាណត្តិទាយក អាណត្តិគាហកត្រូវរាយការណ៍អំពីស្ថានភាពនៃកិច្ចការចាត់ចែងអាណត្តិ ទោះបីនៅពេលណាក៏ដោយ ឬ ត្រូវរាយការណ៍អំពីហេតុនោះដោយគ្មានការយឺតយ៉ាវ នៅក្រោយពេលបានបញ្ចប់អាណត្តិហើយ[7]។ ក្នុងមាត្រានេះ បានបង្ហាញពីសិទ្ធិរបស់អាណត្តិទាយក ក្នុងការទាមទារឲ្យអាណត្តិគាហក ត្រូវរាយការណ៍ពីស្ថានភាពនៃកិច្ចការដែលអាណត្តិទាយកបានប្រគល់សិទ្ធិ ឲ្យធ្វើជំនួសខ្លួននោះទោះបីជាស្ថិតនៅក្នុងស្ថានភាពណាក៏ដោយ ឲ្យតែមានការស្នើសុំទាមទារពីអាណត្តិទាយកនោះ ឬ ក៏ត្រូវរាយការណ៍អំពីកិច្ចការទាំងនោះឲ្យអាណត្តិទាយកបានដឹង ដោយគ្មានការយឺតយ៉ាវ នៅពេលដែលកិច្ចសន្យាអាណត្តិត្រូវបានបញ្ចប់នោះ[8]។

ករណីកិច្ចប្រគល់ អាណត្តិគាហក ត្រូវប្រមូលប្រាក់ និង វត្ថុផ្សេងៗទៀតដែលទទួលបាន តាមការចាត់ចែងកិច្ចការអាណត្តិឲ្យទៅអាណត្តិទាយក។ អាណត្តិគាហក ក៏ត្រូវប្រគល់ផលដែលប្រមូលបានឲ្យទៅអាណត្តិទាយលផងដែរ។ ចំពោះសិទ្ធិដែលអាណត្តិគាហក បានធ្វើលទ្ធកម្មនៅក្នុង ពេលអនុវត្តការក្នុងនាមអាណត្តិទាយកត្រូវផ្ទេរសិទ្ធិនោះឲ្យទៅអាណត្តិទាយក[9]។ នៅពេលដែល កិច្ចសន្យាអាណត្តិត្រូវបានបញ្ចប់នោះ ប្រាក់ ឬ វត្ថុផ្សេងទៀត មានដូចជា ឡាន ម៉ូតូ ទូរសព្ទ័ កុំព្យូទ័រ ជាដើម ដែលអាណត្តិគាហកបានទទួលពីអាណត្តិទាយក តាមរយៈអានុភាពនៃកិច្ចសន្យាអាណត្តិនោះ គឺត្រូវតែប្រគល់ប្រាក់ ឬ វត្ថុទាំងនោះឲ្យដល់អាណត្តិទាយកវិញ។ ចំពោះវត្ថុដែលអាចមានផលនោះដូចជា ផ្ទះ ដីចំការជាដើម ដែលអាចមានផលនោះ អាណត្តិគាហកមិនត្រឹមតែប្រគល់ ផ្ទះ ឬ ដីចំការប៉ុណ្ណោះទេ តែត្រូវប្រគល់ទាំងផលដែលបានទទួលពីផ្ទះ ឬ ដីចំការនោះទៀតផង។ ម្យ៉ាងវិញទៀត ចំពោះសិទ្ធិទាំងឡាយណា ដែលអាណត្តិ

[7] មាត្រា ៦៤១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[8] នីតិកិច្ចសន្យាពិសេស រៀបរៀងដោយ អៀង សំណាង បោះពុម្ពនៅឆ្នាំ២០១៤

[9] មាត្រា ៦៤២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

គាហាកបានទទួលពីអាណត្តិទាយក សម្រាប់បំពេញការងារទាំងឡាយ ក៏ត្រូវប្រគល់ឲ្យដល់អាណត្តិទាយកនៅពេលបំពេញកិច្ចការចប់។

ករណីកិច្ចសងសំណង នៃការខូចខាត ដោយសារតែប្រាក់ដែលអាណត្តិគាហាកទទួលបានពីតតិយជនក្នុងកំឡុងពេល ចាត់ចែងកិច្ចការអាណត្តិជាទ្រព្យសម្បត្តិរបស់អាណត្តិទាយក ដូច្នេះអាណត្តិគាហាកមានករណីកិច្ចសងសំណងការខូចខាតមិនមែនត្រឹមតែការប្រាក់ក្នុងកំឡុងពេលនៃការឃើតយ៉ាវប៉ុណ្ណោះទេ តែថែមទាំងបានមានករណីកិច្ចសងសំណងការខូចខាតដទៃផ្សេងទៀត។ ប្រសិនបើអាណត្តិគាហាកបានប្រើប្រាស់ប្រាក់ដែលត្រូវប្រគល់ឲ្យទៅអាណត្តិទាយក ឬ បានប្រើប្រាស់ដែលទុកប្រើសម្រាប់ផលប្រយោជន៍នោះ ដើម្បីខ្លួន ត្រូវបង់ការប្រាក់ដោយគិតចាប់ពីថ្ងៃដែលបានប្រើប្រាស់ប្រាក់នោះ[10]។ ប្រសិនបើមានខូចខាត ត្រូវទទួលខុសត្រូវសងសំណងនោះ។ ក្នុងន័យនេះ ចង់បញ្ជាក់ពីករណីដែលអាណត្តិគាហាកបានយកប្រាក់ ដែលខ្លួនបានទទួលពីអាណត្តិទាយក តាមរយៈអនុភាពនៃកិច្ចសន្យាអាណត្តិ ដើម្បីយកទៅប្រើប្រាស់សំរាប់កិច្ចការអាណត្តិនោះ តែបែរជាយកប្រាក់នោះ ទៅប្រើប្រាស់សំរាប់ជាប្រយោជន៍របស់ខ្លួនទៅវិញ អាណត្តិគាហាកមានករណីកិច្ចត្រូវសងនូវចំនួនប្រាក់ដែលខ្លួនបានយកនោះ រួមទាំងចំនួនការប្រាក់គិតចាប់ពីថ្ងៃដែលខ្លួនបានយកប្រាក់នោះទៅប្រើប្រាស់ជាប្រយោជន៍របស់ខ្លួន ទៅឲ្យអាណត្តិទាយកវិញ ។ ករណីដែលមានការខូចខាតកើតឡើងដោយសារតែទង្វើនោះ អាណត្តិគាហាកក៏ត្រូវមានករណីយកិច្ចសងការខូចខាតដែលបានកើតឡើងដោយជាក់ស្តែងផងដែរ ។

## ២.២ ករណីកិច្ចរបស់អាណត្តិទាយក

ករណីកិច្ចបង់កម្រៃក្នុងករណីដែរ ពុំបានកំនត់ជាពិសេស ក្នុងកិច្ចសន្យាអាណត្តិគាហាក ពុំអាចទាមទារកម្រៃចំពោះ អាណត្តិទាយកបានឡើយ។ ជាគោលការណ៍អាណត្តិមិនយកកម្រៃ[11]។

ក្នុងករណីនៃ អាណត្តិដោយយកកម្រៃ អាណត្តិគាហាក មិនអាចទាមទារកម្រៃបានឡើយ បើមិនបានបញ្ចប់ការអនុវត្តន៍ករណីកិច្ចដែលត្រូវតាមអាណត្តិរួចហើយទេ

[10] មាត្រា ៦៥៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[11] នីតិកិច្ចសន្យាពិសេស រៀបរៀងដោយ លោកសាស្ត្រចារ្យ ខាំ សុមករា និង យស បានចំរុង ឆ្នាំ២០១៣

។ បើបានកំណត់កំឡុងពេល អាណត្តិគាហក អាចទាមទារបាននៅក្រោយពេលដែលកំឡុងពេលបានកន្លងផុត។ ដូចគ្នាដែរ ប្រសិនបើករណីអាណត្តិដោយយកកម្រៃ អាណត្តិគាហកអាចទាមទារកម្រៃបាន លុះត្រាតែខ្លួនបានអនុវត្តន៍នូវករណីកិច្ច នៅក្នុងកិច្ចសន្យាអាណត្តិ បានចប់សព្វគ្រប់រួចហើយ។ ផ្ទុយទៅវិញ ប្រសិនបើការអនុវត្តន៍នូវករណីកិច្ចមិនទាន់បានចប់នៅឡើយទេ អាណត្តិគាហកមិនមានសិទ្ធិទាមទារកម្រៃពីអាណត្តិទាយកបានឡើយ។ លើកលែងតែភាគីនៃ កិច្ចសន្យាអាណត្តិបានកំណត់នូវអំឡុងពេលជាក់លាក់ណាមួយ មានន័យថា កំឡុងពេលមួយត្រូវបានបញ្ចប់គឺ ត្រូវផ្តល់កម្រៃម្តង ទើបអាណត្តិគាហកអាចមានសិទ្ធិទាមទារកម្រៃបាន។

បើអាណត្តិ ត្រូវបានបញ្ចប់ការអនុវត្តន៍ នៅពាក់កណ្តាលទី ដោយសារហេតុដែល មិនមែនជាការទទួលខុសត្រូវរបស់អាណត្តិគាហក អាណត្តិគាហក អាចទាមទារកម្រៃបានតាមសមាមាត្រនៃភាគដែលបានអនុវត្តន៍រួចហើយនោះ។ នៅក្នុងកិច្ចសន្យាអាណត្តិ ប្រសិនការអនុវត្តន៍ត្រូវបានបញ្ចប់នៅពាក់កណ្តាលទី ដោយបណ្តាលមកពីមូលហេតុដទៃផ្សេងទៀត មិនមែនជាកំហុសរបស់អាណត្តិគាហកនោះ អាណត្តិគាហកអាចទាមទារកម្រៃពីអាណត្តិទាយកបាន ដោយគិតតាមសមាមាត្រ និង ភាគនៃករណីកិច្ចចាត់ចែងកិច្ចការអាណត្តិដោយប្រុងប្រយត្ន័ ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត (កាតព្វកិច្ចផ្តល់មធ្យោបាយ) ទោះបីជាកិច្ចការអាណត្តិត្រូវបានបញ្ចប់ពាក់កណ្តាលទីក៏ដោយ ក៏អាណត្តិគាហក អាចទាមទារកម្រៃនៅក្នុងទំហំសមរម្យបានដែរ។ ករណីនេះវាខុសពីកិច្ចសន្យាម៉ៅការ ត្រង់ថា កិច្ចសន្យាម៉ៅការ អ្នកម៉ៅការមានករណីកិច្ចសម្រេចការងារ (កាតព្វកិច្ចសម្រេចផល) ឲ្យបានចប់ តែប្រសិនកិច្ចសន្យាត្រូវបានបញ្ចប់នៅពាក់កណ្តាលទីនោះដោយមិនបានសម្រេចការងារទេនោះ អ្នកម៉ៅការត្រូវទទួលបន្ទុកនូវហានិភ័យ មានន័យថា មិនអាចទាមទារកម្រៃពីម្ចាស់បានឡើយ។

ករណីកិច្ចបង់សោហ៊ុយជាមុន បើសិនបើមាននូវតម្រូវការ ចាំបាច់លើសោហ៊ុយ សម្រាប់ការចាត់ចែងកិច្ចការអាណត្តិ អាណត្តិទាយកត្រូវបង់សោហ៊ុយនោះជាមុន តាមការទាមទាររបស់អាណត្តិគាហក[12]។ សោហ៊ុយជាការចាំបាច់សម្រាប់ចាត់ចែងនូវកិច្ចការអាណត្តិ ដូចនេះករណីដែលមានការទាមទារជាមុនរបស់អាណត្តិគា

---

[12] មាត្រា ៦៤៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ហាក ដែលតម្រូវឲ្យអាណត្តិទាយកបង់សោហ៊ុយជាមុន ករណីនេះ អាណត្តិទាយកចាំបាច់ត្រូវបង់សោហ៊ុយនោះឲ្យអាណត្តិគាហក ដើម្បីចាត់ចែងកិច្ចការអាណត្តិឲ្យបានទាន់ពេលវេលា[13]។

ករណីកិច្ច សងសំណងការខូចខាត ប្រសិនបើ បានទទួលការខូចខាតដែលមិនមែនបណ្តាលមកពីកំហុសរបស់ខ្លួន នៅក្នុងការចាត់ចែងកិច្ចការអាណត្តិទេ អាណត្តិគាហក អាចទាមទារសំណងនោះ ពីអាណត្តិទាយកបាន។ ប៉ុន្តែ ប្រសិនបើការខូចខាតនោះ កើតឡើងដោយចេតនា ឬ កំហុសរបស់តតិយជន អាណត្តិគាហកអាចទាមទារសំណងចំពោះអាណត្តិទាយកត្រឹមកម្រិត ដែលបានទទួលសំណងពីតតិយជននោះតែប៉ុណ្ណោះ[14]។ មាត្រានេះមានន័យថា នៅក្នុងការចាត់ចែងកិច្ចសន្យាអាណត្តិ ករណីដែលអាណត្តិគាហកបានទទួលរង នូវការខូចខាតដោយកត្តាណាមួយ ដែលមិនមែនកើតឡើងពីកំហុសរបស់ខ្លួននោះ អាណត្តិគាហកអាចទាមទារសំណងនៃការខូចខាតនោះពីអាណត្តិទាយកបាន ព្រោះការទទួលខុសត្រូវរបស់អាណត្តិទាយកនៅក្នុងមាត្រានេះ គឺជាការទទួលខុសត្រូវដោយគ្មានកំហុស មានន័យថាទោះអាណត្តិទាយកគ្មានកំហុស ក៏ត្រូវទទួលខុសត្រូវដែរ (មិនចាំបាច់មានកំហុសរបស់អាណត្តិទាយកដើម្បីទាមទារឲ្យអាណត្តិទាយកទទួលខុសត្រូវទេ។ ម្យ៉ាងទៀត ក្នុងករណីដែលការខូចខាតបណ្តាលមកពីកំហុសដោយមានចេតនា ឬ មានកំហុសរបស់តតិយជនណាមួយនោះ អាណត្តិគាហកក៏នៅតែមានសិទ្ធទាមទារសំណងការខូចខាតនោះ ពីអាណត្តិទាយកបានដែរ ដែលត្រឹមកម្រិតដែលខ្លួន អាចទទួលសំណងនោះពីតតិយជនប៉ុណ្ណោះ។

ឧទាហរណ៍ កញ្ញា ចាន់ បានផ្ញើរឲ្យលោក ស៊ីថាន ឲ្យយកនាឡិការទៅឲ្យប្អូនប្រុសរបស់នាងនៅខេត្តកំពង់ចាមតាមរថយន្តក្រុងមួយ ដោយថ្លៃសេវារថយន្តក្រុងតំលៃ ១០០០០រៀល ដោយដោយលោក ស៊ីថាន ជាអ្នកចេញថ្លៃសេវារថយន្តក្រុងជំនួសកញ្ញា ចាន់ សិន។ តែដោយសារការមិនប្រុងប្រយត្ន័របស់អ្នករថយន្តក្រុង បានធ្វើឲ្យបាត់នាឡិការរបស់កញ្ញា ចាន់។ តាមអង្គហេតុ ការបាត់នាឡិការ កើតឡើងដោយសារ

[13] នីតិកិច្ចសន្យាពិសេស រៀបរៀងដោយ អៀង សំណាង បោះពុម្ពលើកទី១ ឆ្នាំ ២០១៤

[14] មាត្រា៦៤៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ការមិនប្រុងប្រយត្ន័របស់អ្នករថយន្តឈ្នួល។ ដូចនេះ លោក ស៊ីថាន មានសិទ្ធិទាមទារឲ្យកញ្ញា ចាន់ សងប្រាក់ចំនួន ១០០០០ រៀលដែលខ្លួនបានចំណាយលើសេវាបញ្ញើនោះបាន។ ចំណែកការបាត់នាឡិការដៃនោះ កញ្ញា ចាន់ អាចទាមទារនូវសំណងការខូចខាតនោះអ្នករថយន្តក្រុង ដែលមានកំហុស។

## ៣. ការបញ្ចប់កិច្ចសន្យាអាណត្តិ

### ៣.១ ការរំលាយកិច្ចសន្យាអាណត្តិ

ជាគោលការណ៍ យោងតាមមាត្រា ៦៤៧ នៃក្រមរដ្ឋប្បវេណី កិច្ចសន្យាអាណត្តិអាចត្រូវបានរំលាយនៅពេលណាក៏បាន។ មាត្រានេះបានបញ្ជាក់យ៉ាងច្បាស់ថា កិច្ចសន្យាអាណត្តិ គឺបានពឹងផ្អែក ទាំងស្រុងទៅលើការទុកចិត្ត ទៅវិញទៅមកមករវាងអាណត្តិគាហក និង អាណត្តិទាយក ជាគោលការណ៍ កិច្ចសន្យាត្រូវគោរពតាម (Pacta Sunt Servanda)[15] ដូចនេះ ច្បាប់បានផ្តល់សិទ្ធិឲ្យភាគីមានសេរីភាពនៅក្នុងការបង្កើត និង ការរំលាយកិច្ចសន្យាបានគ្រប់ពេលវេលាទាំងអស់ ដោយឆន្ទៈរបស់គូភាគីដោយផ្ទាល់។ ក្នុងន័យនេះបង្ហាញថា ការរំលាយកិច្ចសន្យាអាណត្តិគូភាគីមានសិទ្ធិរំលាយនៅពេលណាក៏បាន ដូចជា ពេលកំពុងអនុវត្តន៏ករណីកិច្ច ឬ អនុវត្តន៏កិច្ចជិតដល់រយៈពេលកំណត់ក៏ដោយ ភាគីអាចមានសិទ្ធិរំលាយកិច្ចសន្យាអាណត្តិនោះបានដែរ។ ទន្ទឹមនឹងច្បាប់ចែងពីសិទ្ធិនៅក្នុងការរំលាយកិច្ចសន្យានេះ ក៏មាននូវករណីកិច្ចមួយចំនួនដែលអាចបណ្តាលឲ្យមាននូវការខូចខាតកើតឡើង ដោយសារអានុភាពនៃការរំលាយកិច្ចសន្យា។ ករណីនេះ ច្បាប់តម្រូវឲ្យភាគី ត្រូវសងសំណងការខូចខាត[16] ប្រសិនបានរំលាយកិច្ចសន្យាអាណត្តិក្នុងកំឡុងពេល ដែលធ្វើឲ្យខូចផលប្រយោជន៏របស់ភាគីម្ខាងទៀត។ ប៉ុន្តែករណីនេះ មិនត្រូវបានយកមកអនុវត្តន៏ឡើយ ប្រសិនមានមូលហេតុដែលមិនអាចជៀសវាងបាន។

### ៣.២ អានុភាពនៃការរំលាយ

ក្នុងករណីដែលបានរំលាយកិច្ចសន្យាអាណត្តិ អនុភាពនៃការរំលាយនោះកើតឡើងដោយឆ្ពោះទៅរកអនាគតតែប៉ុណ្ណោះ។ ប៉ុន្តែករណីនេះ ពុំរារាំងលើការទាមទារ

[15] មេរៀនស្តីពីច្បាប់កិច្ចសន្យា ភាគទី២ រៀបរៀងដោយ លោកមេធាវីសាស្ត្រាចារ្យ កែ វីទ្ធិ ឆ្នាំ២០១២

[16] មាត្រា ២០០៤ និង មាត្រា ២០០៧ នៃក្រមរដ្ឋប្បវេណីបារាំង

សំណាងនៃការខូចខាតចំពោះការរំលាយកិច្ចសន្យានោះឡើយ ប្រសិនបើភាគីណាមួយមានកំហុស[17]។ មាត្រានេះមានន័យថា ជាគោលការណ៍អនុភាពនៃការរំលាយកិច្ចសន្យា គឺមានអនុភាពប្រតិសកម្ម (អនុភាពត្រលប់ថយក្រោយ) គឺត្រូវចាត់ទុកថាគ្មានតាំងពីដំបូងមកម្លេះ។ ដូចនេះគូភាគីនៃកិច្ចសន្យា គឺត្រូវបានរួចផុតពីកាតព្វកិច្ចទាំងអស់ ប៉ុន្តែករណីដែលភាគីបានអនុវត្តន៍កាតព្វកិច្ចរួចហើយ ដោយសារអានុភាពនៃកិច្ចសន្យានោះ នៅពេលកិច្ចសន្យាត្រូវបានរំលាយ ត្រូវធ្វើបដិទាន (ប្រគល់) នូវវត្ថុដែលខ្លួនបានទទួលទៅភាគីម្ខាងទៀត។ ករណីនេះ យើងមិនអាចយកអនុវត្តន៍លើកិច្ចសន្យាអាណត្តិបានឡើយ ព្រោះកិច្ចសន្យាអាណត្តិគឺជាកិច្ចសន្យាបន្ត ហើយមាត្រា ៦៥៨ នៃក្រមរដ្ឋប្បវេណីក៏បានចែងថា អនុភាពនៃការរំលាយកិច្ចសន្យាអាណត្តិកើតឡើងចំពោះតែអនាគត់តែប៉ុណ្ណោះ ហើយគ្មានអនុភាពប្រតិសកម្មទេ។ ជាមួយគ្នានេះអានុភាពនៃកិច្ចសន្យាអាណត្តិនេះ វាមានលក្ខណៈស្រដៀងគ្នា និង អានុភាពភតិសន្យាដែរ ព្រោះប្រភេទនៃអនុភាពនៃកិច្ចសន្យា គ្មានអនុភាពប្រតិសកម្ម[18]។

### ៣.៣ មូលហេតុនៃការបញ្ចប់កិច្ចសន្យាអាណត្តិ

យោងតាមមាត្រា ៦៥៩ នៃក្រមរដ្ឋប្បវេណី កិច្ចសន្យាអាណត្តិត្រូវបានបញ្ចប់ដោយសារមូលហេតុដូចខាងក្រោម៖

- បើអាណត្តិទាយក ឬ អាណត្តិគាហកបានទទមរណភាព។ នៅពេលដែលភាគីណាមួយនៃកិច្ចសន្យា ដែលមានអាណត្តិទាយក ឬ អាណត្តិគាហក បានទទួលមរណភាព ក្នុងពេលកិច្ចសន្យាកំពុងមានសុពលភាព ជាហេតុឲ្យកិច្ចសន្យាអាណត្តិនោះត្រូវបញ្ចប់។
- ប្រសិនបើអាណត្តិទាយកទទួលបានការប្រកាស ការចាត់ផ្តើមអាណាព្យាបាលទូទៅ ឬ ការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ។
- ប្រសិនបើអាណត្តិទាយក ឬ អាណត្តិគាហកត្រូវបានប្រកាសក្ស័យធន។ ក្នុងចំណោមភាគីទាំងពីរ ប្រសិនបើភាគីណាមួយត្រូវបានតុលាការប្រកាសថាក្ស័យធននោះ កិច្ចសន្យាអាណត្តិត្រូវបានបញ្ចាប់ដែរ។

[17] មាត្រា ៦៥៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[18] នីតិកិច្ចសន្យាពិសេស រៀបរៀងដោយ អៀង សំណាង ឆ្នាំ២០១៥

- ប្រសិនបើអាណត្តិទាយក ឬ អាណត្តិគាហក ដែលជានីតិបុគ្គលត្រូវបានរលាយអស់នូវបុគ្គលភាពគតិយុត្តិ។
- ប្រសិនបើអាណត្តិទាយកឬអាណត្តិគាហក ដែលជានីតិបុគ្គល ត្រូវបានរួមបញ្ចូលជាមួយនីតិបុគ្គលផ្សេង។ គឺនីតិបុគ្គលដែលជា អាណត្តិទាយក ឬ ក៏អាណត្តិគាហក ត្រូវបានរួមបញ្ចូលគ្នាជាមួយនីតិបុគ្គលដទៃផ្សេងទៀត។
- ប្រសិនបើមូលហេតុផ្សេងៗដែលបានកំណត់តាមការ ព្រមព្រៀងរបស់ភាគីបានកើតឡើង។ ចំណុចនេះបានបង្ហាញថា គូភាគីនៃកិច្ចសន្យាអាណត្តិមានសិទ្ធិធ្វើការកំណត់អំពីមូលហេតុនៃការបញ្ចប់កិច្ចសន្យាបាន ។ ព្រោះមូលហេតុនៃការបញ្ចប់កិច្ចសន្យាអាណត្តិដែលបានរៀបរាប់ខាងលើ មិនមានលក្ខណៈដាច់ខាតទេ ដូចគូភាគីមានសេរីភាគពេញទី នៅក្នុងការជ្រើសរើសយកមូលហេតុណាមួយ ដែលភាគីបានព្រមព្រៀងពីករណីខាងលើនេះមកធ្វើជាមូលហេតុនៃការបញ្ចប់កិច្ចសន្យាអាណត្តិបាន ក្នុងកិច្ចសន្យារបស់ខ្លួនក៏បាន។ ករណីសង្គ្រោះបន្ទាន់របស់អាណត្តិគាហកនៅក្រោយពេល បញ្ចប់នៅអាណត្តិ។

ក្នុងករណីដែល បានបញ្ចប់អាណត្តិរួចហើយ ប្រសិនបើស្ថានភាពបន្ទាន់អាណត្តិគាហក សន្តិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អាណត្តិគាហកត្រូវធ្វើការចាត់ចែងដែលចាំបាច់រហូតដល់ពេលអាណត្តិទាយក សន្តិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អាណត្តិទាយកនោះ អាចចាត់ការកិច្ចការនោះបាន[19]។ មាត្រានេះគឺចែងដោយមានគោលបំណងដើម្បីការពារអាណត្តិទាយក ពីការរងនូវការខូចខាតទាំងឡាយណាដែលមិនអាចព្យាករណ៍ទុកជាមុនបាន នៅក្នុងអំឡុងពេលចាប់ផ្តើមពីការបញ្ចប់នូវអាណត្តិរហូតដល់អាណត្តិទាយក ឬ អ្នកផ្សេងទៀតដែលអាចមានសមត្ថភាពអាចចាត់ចែងនូវកិច្ចការអាណត្តិនោះ ដោយខ្លួនឯងបាន ។

### ៣.៤ លក្ខខ័ណ្ឌតតាំងនៃការបញ្ចប់អាណត្តិ

មូលហេតុនៃការបញ្ចប់អាណត្តិ ទោះបីជាមូលហេតុនោះ កើតឡើងចំពោះអាណត្តិទាយកក៏ដោយ ឬ ចំពោះអាណត្តិគាហកក៏ដោយ ពុំអាចយកមកតតាំងជាមួយនឹងភាគីម្ខាងទៀតបានឡើយ បើមិនបានជូនដំណឹងទៅឲ្យភាគីម្ខាងទៀតបានដឹង ឬ

[19] មាត្រា ៦៥០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

បើភាគីម្ខាងទៀតពុំបានដឹងពីមូលហេតុនោះទេ។ មាត្រានេះ គឺចែងដើម្បីការពារភាគីម្ខាងទៀតនៃកិច្ចសន្យាអាណត្តិទៅឲ្យភាគីម្ខាងទៀតបានដឹងជាមុន ក្នុងករណីភាគីម្ខាងទៀតនៃកិច្ចសន្យាអាណត្តិពុំបានដឹងពីមូលហេតុនៃការបញ្ចប់អាណត្តិនោះទេ។

ឧទាហរណ៍ អ្នកស្រីសុភាបានប្រគល់សិទ្ធិលក់ម៉ូតូរបស់ខ្លួនឲ្យទៅកញ្ញា ធីតា ដែលជាក្មួយរបស់គាត់ បន្ទាប់ពីបានទទួលសិទ្ធិនោះ កញ្ញា ធីតា បានយកម៉ូតូ ទៅលក់ឲ្យលោក សៅ។ នៅក្នុងតំណាក់កាលនៃការចចារតំលៃម៉ូតូនោះ ស្រាប់តែអ្នកស្រីសុភា បានបញ្ចប់កិច្ចសន្យាអាណត្តិជាមួយកញ្ញា ធីតា។ យោងតាមស្មារតីនៃមាត្រា ៦៥១ នៃក្រមរដ្ឋប្បវេណី តម្រូវឲ្យអ្នកស្រី សុភា ឬ កញ្ញា ធីតា ត្រូវជូនដំណឹង ទៅលោក សៅ ឲ្យបានដឹងពីករណីបញ្ចប់កិច្ចសន្យាអាណត្តិនេះ ដើម្បីជៀសវាងនូវការខូចខាតផ្សេងៗ ដែលអាចកើតឡើង។

# សេចក្ដីសន្និដ្ឋាន

**CONCLUSIONS**

យោងតាមការបកស្រាយខាងរួចមក យើងអាចធ្វើការសន្និដ្ឋានបានថា នៅក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ គឺតែងតែមានការពឹងពាក់គ្នាទៅវិញទៅមកក្នុងកិច្ចការអ្វីមួយទៅតាមការព្រមព្រៀងរបស់គូភាគីទាំងសងខាង ដូច្នេះហើយទើបនៅក្នុងបណ្ដាប្រទេសមិនថាប្រទេសដែលប្រកាន់យកច្បាប់អង់គ្លូសាក់សុងបែបអាមេរិច អាឡឺមង់ ឬ ប្រពន្ធ័ច្បាប់តាមអង់គ្លេសនោះទេ បានបង្កើតឲ្យមាននូវបទបញ្ញត្តិពិសេសមួយដែលទាក់ទងទៅនឹងកិច្ចសន្យា ព្រោះថាច្បាប់កិច្ចសន្យា គឺជាច្បាប់មួយក៏សំខាន់ក្នុងការជួយសម្រួលដល់កិច្ចរបស់ប្រជាពលរដ្ឋមិនថាក្នុងកិច្ចការជំនួញ ឬ ការប្រាស្រ័យទាក់ទងគ្នានោះទេ។ ជាឧទាហរណ៍ដូចជាក្នុងករណីដែលបុគ្គលម្នាក់មានក្រុមហ៊ុនច្រើន នៅតាមបណ្ដាលប្រទេសនីមួយៗនៅក្នុងពិភពលោក មិនអាចគ្រប់គ្រងក្រុមហ៊ុនទាំងអស់នោះក្នុងពេលតែមួយបាននោះទេ គឺពួកគេត្រូវប្រើប្រាស់របបតំណាង និយាយជារួមទៅគឺចាំបាច់ណាស់ត្រូវតែមាននូវការចាត់តំណាងរបស់ខ្លួនដើម្បីមើលការខុសត្រូវទៅលើក្រុមហ៊ុននោះ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង។

ដូច្នេះហើយទើបគេបង្កើតឲ្យមាននូវច្បាប់រដ្ឋប្បវេណី ឬ ច្បាប់ឯកជនឡើង ព្រោះច្បាប់ទាំងអស់នេះវាទាក់ទងក្នុងវិស័យឯកជន ដោយបានបញ្ញត្តិនូវរបបនៃកិច្ចសន្យានៅក្នុងនោះជាមួយផងដែរ។ ជាគោលការណ៍នៅក្នុងរបបនៃការតំណាងនេះ គឺច្បាប់បានបញ្ញត្តិអំពីការប្រើប្រាស់នូវកិច្ចសន្យាមួយដែលគេហៅថា កិច្ចសន្យាអាណត្តិ គឺជាកិច្ចសន្យាដែលមានអាណត្តិទាយក ប្រគល់សិទ្ធិអំណាចទៅអាណត្តិគាហក ធ្វើការចាត់ចែងកិច្ចការដើម្បីអាណត្តិទាយក។ ហើយភាគីទាំងសងខាងត្រូវមានករណីកិច្ចចំពោះគ្នាទៅវិញទៅមក ចំពោះចំណុចដែលគួរកត់សំគាល់នោះគឺ ភាគីនៃអាណត្តិគាហក មិនត្រូវធ្វើអ្វីឲ្យលើសពីទំហំនៃការព្រមព្រៀងគ្នានោះទេ ជាឧហរណ៍ប្រសិនបើអាណត្តិទាយកបានចាត់ឲ្យធ្វើជាតំណាងចំពោះចលនវត្ថុណាមួយក្នុងការយកទៅបញ្ចាំ ស្រាប់តែអាណត្តិគាហកបានយកវត្ថុនោះទៅលក់ដែលខុសពីពីគោល

ការណ៍ដែលអាណត្តិគាហកប្រគល់ឲ្យ។ ត្រង់ចំណុចនេះក្រមរដ្ឋប្បវេណីក៏បានចែងការពារទៅលើអាណត្តិគាហកផងដែរក្នុងករណីនេះ ប្រសិនបើការលក់នោះមានហេតុផលសមរម្យដែលអាណត្តិទាយកអាចទទួលយកបាន ឬ ដែលអនុវត្តទៅតាមច្បាប់កំណត់ទុកជាមុនទៅលើបញ្ហានេះ។ ប្រសិនបើមិនមានហេតុផលណាមួយដែលជាករណីចាំត្រូវតែលក់វត្ថុនោះទេ គឺថាអាណត្តិគាហកត្រូវជួសជុលនូវចំណងការខូចខាតទៅឲ្យអាណត្តិទាយកវិញ។

អាណត្តិគាហកអាចធ្វើការតំណាងដោយអាណត្តិ ទៅតាមការព្រមព្រៀងដោយមិនយកកម្រៃ ឬ ដោយមិនយកកម្រៃទៅតាមការស្មគ្រ័ចិត្តរបស់ខ្លួន ព្រោះថាវាជាឆន្ទៈរបស់អាណត្តិគាហក ហើយក្រមរដ្ឋប្បវេណីក៏បានចែងផងដែរទៅលើចំណុចដែលអាណត្តិគាហកអាចធ្វើដោយយកកម្រៃក៏បាន ដោយមិនយកកម្រៃក៏បាន ផ្អែកទៅតាមគោលការណ៍ស្មគ្រ័ចិត្ត។ អាណត្តិគាហកត្រូវមានករណីកិច្ចចាត់ចែងអាណត្តិដោយប្រុងប្រយត្ន័ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ក្នុងករណីដែលអាណត្តិគាហកធ្វើផ្ទុយនឹងករណីកិច្ចប្រុងប្រយត្ន័ហើយបានធ្វើឲ្យមានការខូចខាតដល់អាណត្តិទាយក អាណត្តិទាយកអាចទាមទារសំណងនៃការខូចខាតនោះបាន ដូចរៀបរាប់ក្នុងឧទាហរណ៍ខាងលើ។ តែជាផលប្រយោជន៍មួយផងដែរចំពោះអាណត្តិគាហក ក្នុងករណីប្រសិនអាណត្តិគាហក ប្រើជាអាណត្តិដោយមិនយកកម្រៃតុលាការអាចបន្ថយចំនួនទឹកប្រាក់សំណងនៃការខូចខាតនោះ។ លើសពីនេះទៀតអាណត្តិទាយកយកក៏មានករណីកិច្ចក្នុងការបង់កម្រៃ បង់សោហ៊ុយជាមុន និង សំណងនៃការខូចខាតផងដែរ ប្រសិនបើបានទទួលការខូចខាតដែលមិនមែនបណ្តាលមកពីកំហុសរបស់ខ្លួន នៅក្នុងការចាត់ចែងកិច្ចការអាណត្តិទេ អាណត្តិគាហកអាចទាមទារសំណងពីអាណត្តិទាយកបាន។

សរុបមកកិច្ចសន្យាអាណត្តិ វាគឺជាកាតព្វកិច្ចមួយដែលភាគីទាំងសងខាងត្រូវមានករណីកិច្ចចំពោះគ្នាទៅវិញទៅមក ហើយនិងធ្វើការទទួលខុសត្រូវទៅលើទង្វើរបស់ខ្លួន ប្រសិនភាគីណាមួយបំពានទៅលើបញ្ហានេះ និងត្រូវផ្តល់នូវសំណងនៃការខូចខាតទៅឲ្យភាគីម្ខាងទៀតទៅតាមកម្រិត និង ទំហំនៃការខូតខាតនោះ។

# ឧបសម្ព័ន្ធ

# ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

# ជំពូកទី ៧
# អាណត្តិ

**មាត្រា ៦៣៧.-** និយមន័យនៃអាណត្តិ

អាណត្តិសំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាង ហៅថា អាណត្តិទាយក ប្រគល់សិទ្ធិអំណាចឱ្យភាគីម្ខាងទៀត ហៅថា អាណត្តិគាហក ធ្វើការចាត់ចែងកិច្ចការដើម្បីអាណត្តិទាយក ។

**មាត្រា ៦៣៨.-** គោលការណ៍នៃអាណត្តិដោយមិនយកកម្រៃ

១-អាណត្តិអាចធ្វើដោយយកកម្រៃ ឬ មិនយកកម្រៃបាន ។ បើពុំបានបង្ហាញឆន្ទៈអំពីការធ្វើដោយយកកម្រៃទេ ត្រូវសន្មតថាជាអាណត្តិដោយមិនយកកម្រៃ ។

២-បញ្ញត្តិនៃមាត្រា ៦៤៤ (សិទ្ធិទាមទារកម្រៃរបស់អាណត្តិគាហក) នៃក្រមនេះ ត្រូវយកមកអនុវត្តចំពោះកម្រៃ នៅក្នុងករណីនៃអាណត្តិដោយយកកម្រៃ ។

**មាត្រា ៦៣៩.-** ភាពចាំបាច់នៃទម្រង់កិច្ចសន្យា

កិច្ចសន្យាអាណត្តិត្រូវបង្កើតដោយការព្រមព្រៀងរបស់ភាគីតែប៉ុណ្ណោះ ។

**មាត្រា ៦៤០.-** ករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក

១-អាណត្តិគាហក មានករណីយកិច្ចចាត់ចែងកិច្ចការអាណត្តិ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងសុចរិត ដោយផ្អែកតាមអត្ថន័យនៃអាណត្តិ ។ ប៉ុន្តែ បញ្ញត្តិនេះមិនរារាំងចំពោះការបន្ថយករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក តាមការព្រមព្រៀងរបស់ភាគីឡើយ ។

២-ក្នុងករណីដែលអាណត្តិគាហក ធ្វើផ្ទុយនឹងករណីយកិច្ចប្រុងប្រយ័ត្ននៃកថាខណ្ឌទី ១ ខាងលើនេះ ហើយបានធ្វើឱ្យមានការខូចខាតដល់អាណត្តិទាយក អាណត្តិទាយកអាចទាមទារសំណងនៃការខូចខាតនោះពីអាណត្តិគាហកបាន ។ នៅក្នុងករណីនេះ ប្រសិនបើ

ជាអាណត្តិដោយមិនយកកម្រៃ តុលាការអាចបន្ថយចំនួនទឹកប្រាក់សំណងនៃការខូចខាតបាន ។

**មាត្រា ៦៤១.-** ករណីយកិច្ចរាយការណ៍ របស់អាណត្តិគាហក

បើមានការទាមទាររបស់អាណត្តិទាយក អាណត្តិគាហកត្រូវរាយការណ៍អំពីស្ថាន-ភាពនៃកិច្ចការចាត់ចែងអាណត្តិ ទោះបីនៅពេលណាក៏ដោយ ឬ ត្រូវរាយការណ៍អំពីហេតុការណ៍នោះដោយគ្មានការយឺតយ៉ាវ នៅក្រោយពេលដែលបានបញ្ចប់អាណត្តិហើយ ។

**មាត្រា ៦៤២.-** ករណីយកិច្ចប្រគល់ របស់អាណត្តិគាហក

១-អាណត្តិគាហកត្រូវប្រគល់ប្រាក់ និង វត្ថុផ្សេងៗទៀតដែលទទួលបានតាមការចាត់ចែងកិច្ចការអាណត្តិ ឱ្យទៅអាណត្តិទាយក ។ អាណត្តិគាហកក៏ត្រូវប្រគល់ផលដែលប្រមូលបានឱ្យទៅអាណត្តិទាយកផងដែរ ។

២-សិទ្ធិដែលអាណត្តិគាហកបានលទ្ធកម្មនៅក្នុងនាមរបស់ខ្លួនដើម្បីអាណត្តិទាយកត្រូវផ្ទេរសិទ្ធិនោះឱ្យទៅអាណត្តិទាយក ។

**មាត្រា ៦៤៣.-** ករណីយកិច្ចសងសំណងនៃការខូចខាតរបស់អាណត្តិគាហកដែលបានប្រើប្រាក់

ប្រសិនបើអាណត្តិគាហកបានប្រើប្រាក់ដែលត្រូវប្រគល់ទៅឱ្យអាណត្តិទាយក ឬ បានប្រើប្រាក់ដែលទុកប្រើសម្រាប់ផលប្រយោជន៍នោះ ដើម្បីខ្លួន ត្រូវបង់ការប្រាក់ដោយគិតចាប់ពីថ្ងៃដែលបានប្រើប្រាក់នោះ ។ ប្រសិនបើមានការខូចខាត ត្រូវទទួលខុសត្រូវសងសំណងនោះ ។

**មាត្រា ៦៤៤.-** សិទ្ធិទាមទារកម្រៃរបស់អាណត្តិគាហក

១-អាណត្តិគាហក ពុំអាចទាមទារកម្រៃចំពោះអាណត្តិទាយកបានឡើយ ក្នុងករណីដែលពុំបានកំណត់ជាពិសេស ក្នុងកិច្ចសន្យា ។

២-នៅក្នុងករណីនៃអាណត្តិដោយយកកម្រៃ អាណត្តិគាហកមិនអាចទាមទារកម្រៃបានឡើយ បើមិនបានបញ្ចប់ការអនុវត្តករណីយកិច្ចដែលត្រូវតាមអាណត្តិនោះរួចហើយ

ទេ ។ ប៉ុន្តែ បើបានកំណត់កម្រៃតាមអំឡុងពេល អាចទាមទារបាន នៅក្រោយពេលដែល អំឡុងពេលនោះបានកន្លងផុត ។

៣-បើអាណត្តិត្រូវបានបញ្ចប់ការអនុវត្ត នៅពាក់កណ្តាលទី ដោយសារមូលហេតុ ដែលមិនមែនជាការទទួលខុសត្រូវរបស់អាណត្តិគាហក អាណត្តិគាហកអាចទាមទារកម្រៃ បានតាមសមាមាត្រនៃភាគដែលបានអនុវត្តរួចហើយនោះ ។

**មាត្រា ៦៤៥.-** ករណីយកិច្ចបង់សោហ៊ុយជាមុនរបស់អាណត្តិទាយក

ប្រសិនបើមានតម្រូវការចាំបាច់លើសោហ៊ុយសម្រាប់ការចាត់ចែងកិច្ចការអាណត្តិ អាណត្តិទាយកត្រូវបង់សោហ៊ុយនោះជាមុន តាមការទាមទាររបស់អាណត្តិគាហក ។

**មាត្រា ៦៤៦.-** សិទ្ធិទាមទារឱ្យសងមកវិញ ជាអាទិ៍ នូវសោហ៊ុយរបស់អាណត្តិគាហក

១-ប្រសិនបើបានចំណាយប្រាក់ដែលទទួលស្គាល់ថាចាំបាច់សម្រាប់ធ្វើការចាត់ចែងកិច្ចការអាណត្តិ អាណត្តិគាហកអាចទាមទារចំពោះអាណត្តិទាយកឱ្យសងមកវិញ នូវសោហ៊ុយ និង ការប្រាក់បាន ដោយគិតចាប់ពីក្រោយថ្ងៃដែលបានចំណាយសោហ៊ុយនោះ ។

២-ប្រសិនបើបានទទួលបន្ទុកកាតព្វកិច្ចដែលទទួលស្គាល់ថាចាំបាច់សម្រាប់ធ្វើការចាត់ចែងកិច្ចការអាណត្តិ អាណត្តិគាហកអាចឱ្យអាណត្តិទាយកសងកាតព្វកិច្ចនោះជំនួសខ្លួន ឬ បើពុំទាន់ដល់កំណត់ពេលដែលត្រូវសងកាតព្វកិច្ចនោះទេ អាចឱ្យដាក់ប្រាតិភោគដែលសមរម្យបាន ។

៣-ប្រសិនបើបានទទួលការខូចខាត ដែលមិនមែនបណ្តាលមកពីកំហុសរបស់ខ្លួន នៅក្នុងការចាត់ចែងកិច្ចការអាណត្តិទេ អាណត្តិគាហកអាចទាមទារសំណងនោះ ពីអាណត្តិ-ទាយកបាន ។ ប៉ុន្តែ ប្រសិនបើការខូចខាតនោះ កើតឡើងដោយចេតនា ឬ កំហុសរបស់តតិយជន អាណត្តិគាហកអាចទាមទារសំណងចំពោះអាណត្តិទាយកបាន ត្រឹមកម្រិតដែលពុំបានទទួលសំណងពីតតិយជននោះតែប៉ុណ្ណោះ ។

**មាត្រា ៦៤៧.-** ការរំលាយកិច្ចសន្យាអាណត្តិ

១-ភាគីនីមួយៗ អាចរំលាយកិច្ចសន្យាអាណត្តិ នៅពេលណាក៏បាន ។

២-ភាគីម្ខាងត្រូវសងសំណងនៃការខូចខាត ប្រសិនបើបានរំលាយកិច្ចសន្យាអាណត្តិនៅក្នុងអំឡុងពេលដែលធ្វើឱ្យខូចផលប្រយោជន៍ចំពោះភាគីម្ខាងទៀត ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើមានមូលហេតុដែលមិនអាចជៀសវាងបាន ។

**មាត្រា ៦៤៨.-** ការរំលាយកិច្ចសន្យាដែលពុំមានអានុភាពប្រតិសកម្ម

នៅក្នុងករណីដែលបានរំលាយកិច្ចសន្យាអាណត្តិ អានុភាពនៃការរំលាយកិច្ចសន្យានោះកើតមានឡើងដោយឆ្ពោះទៅអនាគតតែប៉ុណ្ណោះ ។ ប៉ុន្តែ ករណីនេះពុំរារាំងលើការទាមទារសំណងនៃការខូចខាតចំពោះការរំលាយកិច្ចសន្យានោះឡើយ ប្រសិនបើភាគីណាម្ខាងមានកំហុស ។

**មាត្រា ៦៤៩.-** មូលហេតុនៃការបញ្ចប់អាណត្តិ

១-ក្រៅពីការរំលាយកិច្ចសន្យាអាណត្តិដោយបញ្ញត្តិនៃមាត្រា ៦៤៧ (ការរំលាយកិច្ចសន្យាអាណត្តិ) នៃក្រមនេះ អាណត្តិត្រូវបញ្ចប់ដោយមូលហេតុដូចខាងក្រោមនេះ :

ក-ប្រសិនបើអាណត្តិទាយក ឬ អាណត្តិគាហក បានទទួលមរណភាព ។

ខ-ប្រសិនបើអាណត្តិទាយក ឬ អាណត្តិគាហក ត្រូវបានប្រកាសធនក្ស័យ ។

គ-ប្រសិនបើអាណត្តិទាយកត្រូវបានទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ ឬ ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ ។

ឃ-ប្រសិនបើអាណត្តិគាហក ត្រូវបានទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ ឬ ការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ ។

ង-ប្រសិនបើអាណត្តិទាយក ឬ អាណត្តិគាហកដែលជានីតិបុគ្គល បានរលាយ ។

ច-ប្រសិនបើអាណត្តិទាយក ឬ អាណត្តិគាហកដែលជានីតិបុគ្គល បានរួមបញ្ចូលជាមួយនីតិបុគ្គលផ្សេង ។

ឆ-ប្រសិនបើមូលហេតុផ្សេងៗដែលបានកំណត់តាមការព្រមព្រៀងរបស់ភាគីបានកើតឡើង ។

២-ភាគីអាចព្រមព្រៀងអំពីការណ៍ដែលអាណត្តិមិនបញ្ចប់ ទោះបីជាមូលហេតុដែលបានកំណត់ចាប់ពីចំណុច ក ដល់ ចំណុច ច នៃកថាខណ្ឌទី ១ ខាងលើនេះ បានកើត

ឡើងក៏ដោយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះមរណភាពរបស់អាណត្តិគាហក ការចាប់ផ្តើមអាណាព្យាបាលទូទៅសម្រាប់អាណត្តិគាហក ឬ ការរលាយ ឬ ការបញ្ចូលនៃអាណត្តិគាហកដែលជានីតិបុគ្គល ។

**មាត្រា ៦៥០.-** ករណីយកិច្ចសង្គ្រោះបន្ទាន់ របស់អាណត្តិគាហក នៅក្រោយពេលបញ្ចប់អាណត្តិ

នៅក្នុងករណីដែលបានបញ្ចប់អាណត្តិហើយ ប្រសិនបើមានស្ថានភាពបន្ទាន់ អាណត្តិគាហក សន្តតិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អាណត្តិគាហកនោះ ត្រូវធ្វើការចាត់ចែងដែលចាំបាច់រហូតដល់ពេលដែលអាណត្តិទាយក សន្តតិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អាណត្តិទាយកនោះ អាចចាត់ការកិច្ចការនោះបាន ។

**មាត្រា ៦៥១.-** ល័ក្ខខ័ណ្ឌតតាំងនៃការបញ្ចប់អាណត្តិ

មូលហេតុនៃការបញ្ចប់អាណត្តិ ទោះបីជាមូលហេតុនោះកើតឡើងចំពោះអាណត្តិទាយកក៏ដោយ ឬ ចំពោះអាណត្តិគាហកក៏ដោយ ពុំអាចយកមកតតាំងជាមួយនឹងភាគីម្ខាងទៀតបានឡើយ បើមិនបានជូនដំណឹងទៅឱ្យភាគីម្ខាងទៀត ឬ បើភាគីម្ខាងទៀតពុំបានដឹងអំពីមូលហេតុនោះទេ ។

# ក្រមរដ្ឋប្បវេណីសង្គមចាស់ ឆ្នាំ១៩៦៧

# ចំពូក ទី ១០

## អំពី អាណត្តិ

មាត្រា ១២៦៨.- អាណត្តិ គឺជាកិច្ចសន្យា ដែលជន ម្នាក់ ឲ្យ អំណាច ទៅ ជន ម្នាក់ទៀត ឲ្យយក ទៅបំពេញ កិច្ចខ្លះ ខាងតុលាការ ក្នុងនាម ខ្លួន និង ការ ខ្លួន ។

មាត្រា ១២៦៩.- អ្នក ដែលឲ្យ អំណាច ទៅគេហៅថា អាណត្តិទាយក; អ្នក ដែលទទួល អំណាច នោះ ហៅថា អាណត្តិគាហក ឬ អ្នក ដំណាង ។

មាត្រា ១២៧០.- ភាគី អាច ព្រមព្រៀងគ្នា អំពីអាណត្តិ ដោយ ឥត ឈ្នួល ឬមាន ឈ្នួល បាន ។ បើកិច្ចសន្យា មិន បាននិយាយ ត្រង់ ទនេះ ទេ, អាណត្តិ នោះ គប្បីសន្និដ្ឋាន ថា ឥតមាន ឈ្នួល ទេ ។

មាត្រា ១២៧១.- អាណត្តិ នោះ នឹងយក ជាការ បាន លុះណា តែ ធ្វើ ជាលាយល័ក្ខ អក្សរ; លិខិត ប្រគល់ អំណាច នេះហៅថា សំបុត្រ ប្រគល់ អំណាច ឬ សិទ្ធិប្រទាន ។

មាត្រា ១២៧២. ជន ទាំងឡាយ ច្រើន នាក់ អាច ឲ្យ អំណាច ខ្លួន ទៅ ដំណាង តែម្នាក់ ចេញការ ក្នុងអត្ថសេចក្តី តែមួយ ជាមួយគ្នា បាន ។ បើ អាណត្តិ នោះមាន ឈ្នួល ដែរ, អាណត្តិទាយក ទាំងអស់ ត្រូវ រួបរួមគ្នា ចេញ ។

មាត្រា ១២៧៣.- អាណត្តិនោះ អាចជាអាណត្តិពិសេសក៏បាន ជាអាណត្តិទូទៅក៏បាន, សេចក្តីក្នុងសិទ្ធិប្រទាន នោះ ត្រូវបញ្ជាក់ពីវិសាលភាពនៃអាណត្តិនោះផង ។

មាត្រា ១២៧៤.- អាណត្តិទាយក មិនអាចឲ្យអំណាចខ្លួនហួសពីខ្លួនមានបានទេ ។

មាត្រា ១២៧៥.- ជនទាំងពួង អាចធ្វើជាតំណាងនៅមុខតុលាការ តាមអំណាចសិទ្ធិប្រទាន តាង បុព្វញាត្តិ, បច្ឆាញាតិខ្លួន ដែលមាន ខាន់ស្លា, ឥតខាន់ស្លា, ឬ សាច់ចិញ្ចឹម, តាង សហព័ទ្ធខ្លួន ដែលមាន ខាន់ស្លា, តាង ញាតិសាខាបង្កើត, រួមឪពុក ឬ រួមម្តាយ ដែលមានខាន់ស្លា, ឥតខាន់ស្លា ឬ សាច់ចិញ្ចឹម ត្រឹមថ្នាក់ទី៤ និង ញាតិពន្ធនៃខ្លួន ត្រឹមថ្នាក់ទី៤ ដែរ ។

មាត្រា ១២៧៦.- បើអ្នកតំណាង មិនមែនជាញាតិ តាមល័ក្ខខ័ណ្ឌ ដូចមានអធិប្បាយ ខាងលើនេះទេ, តុលាការ អាចមិនព្រមទទួល អ្នកតំណាងនោះ ដោយមិនបាច់ប្រាប់ហេតុបាន ។

មាត្រា ១២៧៧.- អ្នកតំណាងត្រូវឲ្យដល់អាណត្តិទាយក នូវពត៌មានគ្រប់ប្រការ ដែលអាណត្តិទាយក ដណ្តឹងសួរ អំពីស្ថានភាពនៃរឿង ដែលគេពឹងពាក់ខ្លួន ។

មាត្រា ១២៧៨.- អ្នកតំណាង ត្រូវរាយកច់ការក្រោយ ដែល

ខ្លួន បាន ប្រតិបត្តិ តាមអាណត្តិ រួចហើយ ។ ខ្លួន ត្រូវ ទទួល ខុសត្រូវ អំពីកំហុស របស់ ខ្លួន ផង ។

មាត្រា ១២៧៩ .— នាកាល មាន អាណត្តិទាយក ប្តឹង ពីអ្នកតំណាង ខ្លួន, តុលាការ ត្រូវ រក កំហុស តំណាង មាន ឈ្នួល ឲ្យតឹងរឹងជាងតំណាង ឥត ឈ្នួល ។

មាត្រា ១២៨០.— អ្នកតំណាង ត្រូវ យកចិត្តទុកដាក់ បំពេញ នូវអាណត្តិខ្លួន ឲ្យហ្មត់ចត់ និង ឲ្យរហ័សរហៃ ផង ។

មាត្រា ១២៨១ .— អាណត្តិទាយក ត្រូវ ចេញ សោហ៊ុយ ដាច់ខាត ក្នុងការ ដែលខ្លួន ឲ្យអាណត្តិ ទៅគេ ធ្វើ នោះ ។

មាត្រា ១២៨២.— ១ សន្យា ទាំងឡាយ ដែលអ្នកតំណាង បានធ្វើក្នុងនាម អាណត្តិទាយក ក្នុងព្រំដែន នៃអំណាច ដែលអាណត្តិទាយកឲ្យមក នោះ ត្រូវទុក ជាបានការ ទាំងអស់ ។

មាត្រា ១២៨៣ .— អំណាច ដែលអាណត្តិ ទាយក បានឲ្យនោះ នឹងដក វិញ បាន មិនបាច់ ប្រាប់ ហេតុ ឡើយ ។

មាត្រា ១២៨៤.— កិច្ចការ ទាំងឡាយ, ទាំងពួង ដែលអ្នកតំណាង បានធ្វើ ក្រោយ ដែលអាណត្តិទាយក បានដក អំណាច ហើយនោះ ត្រូវ ទុក ជាមោឃៈ ។

មាត្រា ១២៨៥ .— បើ អាណត្តិទាយក ឬ អ្នកតំណាង ស្លាប់,

អំណាច ដែលឲ្យ នោះ ត្រូវ លោយ ។

មាត្រា ១២៨៦.- អ្នក, ដែលកាន់កាប់ គ្មាន សិទ្ធិប្រទាន នូវ ការងារ របស់ជនដទៃ ដើម្បីកុំឲ្យ គេ មាន ព្យសនកម្ម, ត្រូវមាន កាតព្វកិច្ច ដូចខ្លួន ជាអ្នកតំណាង ដែរ; សិទ្ធិ នៃអ្នក ដែលធ្វើការជួស ជន ដទៃ នេះ ត្រូវគិត ដូចមាន ចែង ក្នុងមាត្រា៨២៩·៨២៦នោះ ។

# ក្រមរដ្ឋប្បវេណីជប៉ុន ឆ្នាំ១៨៩៦

## 第十節　委任
## Section 10 Mandates

（委任）
(Mandates)

第六百四十三条　委任は、当事者の一方が法律行為をすることを相手方に委託し、相手方がこれを承諾することによって、その効力を生ずる。

Article 643 A mandate shall become effective when one of the parties mandates the other party to perform a juristic act, and the other party accepts the mandate.

（受任者の注意義務）
(Duty of Care of Mandatary)

第六百四十四条　受任者は、委任の本旨に従い、善良な管理者の注意をもって、委任事務を処理する義務を負う。

Article 644 A mandatary shall assume a duty to administer the mandated business with the care of a good manager compliance with the main purport of the mandate.

（受任者による報告）
(Reports by Mandatary)

第六百四十五条　受任者は、委任者の請求があるときは、いつでも委任事務の処理の状況を報告し、委任が終了した後は、遅滞なくその経過及び結果を報告しなければならない。

Article 645 A mandatary must, if so requested by the mandator, report the current status of the administration of the mandated business at any time, and must report the process and results without delay upon completion of the mandate.

（受任者による受取物の引渡し等）
(Delivery of Received Things by Mandatary)

第六百四十六条　受任者は、委任事務を処理するに当たって受け取った金銭その他の物を委任者に引き渡さなければならない。その収取した果実についても、同様とする。

Article 646 (1) The mandatary must deliver to the mandator monies and other Things that he/she has received during the course of administering the mandated business. The same shall apply to fruits the mandatary has reaped.

２　受任者は、委任者のために自己の名で取得した権利を委任者に移転しなければならない。

(2) The mandatary must transfer to the mandator rights the mandatary has acquired in his/her own name on behalf of the mandator.

（受任者の金銭の消費についての責任）

(Mandatary's Responsibility for Consumption of Monies)

第六百四十七条　受任者は、委任者に引き渡すべき金額又はその利益のために用いるべき金額を自己のために消費したときは、その消費した日以後の利息を支払わなければならない。この場合において、なお損害があるときは、その賠償の責任を負う。

Article 647 If the mandatary has consumed monies for his/her personal benefit that the mandatary is to deliver to the mandator, or any monies that are to be used for the benefit of the mandator, the mandatary must pay interest for the period from the day of that consumption. In such cases, if any damages still remain, the mandatary shall be liable to compensate for the same.

（受任者の報酬）

(Remuneration for Mandatary)

第六百四十八条　受任者は、特約がなければ、委任者に対して報酬を請求することができない。

Article 648 (1) In the absence of any special agreements, the mandatary may not claim remuneration from the mandator.

２　受任者は、報酬を受けるべき場合には、委任事務を履行した後でなければ、これを請求することができない。ただし、期間によって報酬を定めたときは、第六百二十四条第二項の規定を準用する。

(2) In cases where the mandatary is to receive remuneration, the mandatary may not claim the same until and unless he/she has performed the mandated business; provided, however, that if the remuneration is specified with reference to period, the provisions of Paragraph 2 of Article 624 shall apply mutatis mutandis.

３　委任が受任者の責めに帰することができない事由によって履行の中途で終了したときは、受任者は、既にした履行の割合に応じて報酬を請求することができる。

(3) If the mandate terminates during performance due to reasons not attributable to the mandatary, the mandatary may demand remuneration in proportion to the performance already completed.

（受任者による費用の前払請求）

(Mandatary's Claims for Advance for Costs)

第六百四十九条　委任事務を処理するについて費用を要するときは、委任者は、受任者の請求により、その前払をしなければならない。

Article 649 If costs will be incurred in administering the mandated business, the mandator must, at the request of the mandatary, pay an advance for those costs.

（受任者による費用等の償還請求等）

(Mandatary's Claims for Reimbursement of Expense)

第六百五十条　受任者は、委任事務を処理するのに必要と認められる費用を支出したときは、委任者に対し、その費用及び支出の日以後におけるその利息の償還を請求することができる。

Article 650 (1) If the mandatary has incurred costs found to be necessary for the administration of the mandated business, the mandatary may claim reimbursement of those costs from the mandator and any interest on the same from the day the costs were incurred.

２　受任者は、委任事務を処理するのに必要と認められる債務を負担したときは、委任者に対し、自己に代わってその弁済をすることを請求することができる。この場合において、その債務が弁済期にないときは、委任者に対し、相当の担保を供させることができる。

(2) If the mandatary has incurred any obligation found to be necessary for the administration of the mandated business, the mandatary may demand that the mandator perform the obligation on the mandatary's behalf. In such cases, if the obligation has not yet fallen due, the mandatary may require the mandator to tender reasonable security.

３　受任者は、委任事務を処理するため自己に過失なく損害を受けたときは、委任者に対し、その賠償を請求することができる。

(3) If the mandatary suffers any loss due to the administration of the mandated business without negligence in the mandatary, he/she may claim compensation for the loss from the mandator.

（委任の解除）

(Cancellation of Mandate)

第六百五十一条　委任は、各当事者がいつでもその解除をすることができる。

Article 651 (1) A mandate may be cancelled by either party at any time.

２　当事者の一方が相手方に不利な時期に委任の解除をしたときは、その当事者の一方は、相手方の損害を賠償しなければならない。ただし、やむを得ない事由があったときは、この限りでない。

(2) If one of the parties cancels a mandate at a time that is detrimental to the other

party, the former party must compensate the damages suffered by the other party; provided, however, that this shall not apply if there are unavoidable grounds.

（委任の解除の効力）

(Effect of Cancellation of Mandate)

第六百五十二条　第六百二十条の規定は、委任について準用する。

Article 652 The provision of Article 620 shall apply mutatis mutandis to mandates.

（委任の終了事由）

(Grounds for Termination of Mandate)

第六百五十三条　委任は、次に掲げる事由によって終了する。

Article 653 A mandate shall terminate when:

一　委任者又は受任者の死亡

(i) The mandator or mandatary dies;

二　委任者又は受任者が破産手続開始の決定を受けたこと。

(ii) The mandator or mandatary is subject to a ruling for the commencement of bankruptcy procedures;

三　受任者が後見開始の審判を受けたこと。

(iii) The mandatary is subject to an order for the commencement of guardianship.

（委任の終了後の処分）

(Disposition after Termination of Mandate)

第六百五十四条　委任が終了した場合において、急迫の事情があるときは、受任者又はその相続人若しくは法定代理人は、委任者又はその相続人若しくは法定代理人が委任事務を処理することができるに至るまで、必要な処分をしなければならない。

Article 654 In cases where a mandate has terminated, if there are pressing circumstances, the mandatary or his/her heir or legal representative must effect necessary dispositions until the time when the mandator or his/her heir or legal representatives is able to take charge of the mandated business.

（委任の終了の対抗要件）

(Requirement for Perfection of Termination of Mandate)

第六百五十五条　委任の終了事由は、これを相手方に通知したとき、又は相手方がこれを知っていたときでなければ、これをもってその相手方に対抗することができない。

Article 655 The grounds of termination of mandate may not be asserted against the other party unless the other party was notified of or knew of the same.

（準委任）

(Quasi-Mandate)

第六百五十六条　この節の規定は、法律行為でない事務の委託について準用する。

Article 656 The provisions of this Section shall apply mutatis mutandis to mandates of business that do not constitute juristic acts.

# ក្រមរដ្ឋប្បវេណីបារាំង ឆ្នាំ១៨៨៩

## Art. 1986

An agency is gratuitous, unless there is an agreement to the contrary.

## Art. 1992

An agent is liable not only for intentional breach, but also for faults committed in his management.

Nevertheless, the liability for faults is implemented less rigorously against the one whose agency is gratuitous than

against the one receiving a salary.

## Art. 1993

Every agent is bound to account for his management, and to return to the principal all that he received by virtue of

his power of attorney, even where what he received was not owed to the principal.

## Art. 1999

A principal must reimburse the agent for the advances and expenses which the latter made for the performance of

the agency, and pay him his salary where it has been promised.

Where no fault may be ascribed to the agent, the principal may not dispense with making those reimbursements

and payments, even if the matter did not succeed, and he may not have the amount of the expenses and advances

reduced on the pretext that they could have cost less.

## Art. 2000

A principal must also compensate the agent for the losses which the latter has incurred on the occasion of his

management, without an imprudent act being ascribable to him.

## Art. 2006

The appointment of a new agent for the same affair involves revocation of the first one, from the day when notice of it has been given to the latter.

# ឯកសារយោង

## REFERENCES


1. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។
2. សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
3. នីតិកិច្ចសន្យាពិសេស រៀបរៀងដោយ អៀង សំណាង បោះពុម្ពនៅឆ្នាំ២០១៤។
4. សេចក្តីផ្តើមនីតិរដ្ឋប្បវេណី និពន្ធដោយ លោកសាស្ត្រាចារ្យ ណូមឺរ៉ា តូយ៉ូហ៊ីរ៉ូ កែសម្រួលចុងក្រោយ រាជធានីភ្នំពេញ ខែតុលា ឆ្នាំ២០១៥។
5. មេរៀនស្តីពីនីតិកិច្ចសន្យា រៀបរៀងដោយ លោកមេធាវីសាស្ត្រាចារ្យ កែ រឹទ្ធ អនុបណ្ឌិតនីតិសាស្ត្រ ជំនាញនីតិឯកជន ឆ្នាំ២០១២។
6. នីតិកិច្ចសន្យាពិសេស រៀបរៀងដោយ លោក សាស្ត្រាចារ្យ យស បានចំរុង និង លោកសាស្ត្រាចារ្យ ខាំ សុមករា នៃសាកលវិទ្យាល័យបៀលប្រាយ ឆ្នាំ២០១៣។

# History of Contract Law

*In common law legal systems, a contract (or informally known as an agreement in some jurisdictions) is an agreement having a lawful object entered into voluntarily by two or more parties, each of whom intends to create one or more legal obligations between them. The elements of a contract are "offer" and "acceptance" by "competent persons" having legal capacity who exchanges "consideration" to create "mutuality of obligation."*

*Contract law varies greatly from one jurisdiction to another, including differences in common law compared to civil law, the impact of received law, particularly from England in common law countries, and of law codified in regional legislation. Regarding Australian Contract Law for example, there are 40 relevant acts which impact on the interpretation of contract at the Commonwealth (Federal / national) level, and an additional 26 acts at the level of the state of NSW. In addition there are 6 international instruments or conventions which are applicable for international dealings, such as the United Nations Convention on Contracts for the International Sale of Goods.*

*Contract law is based on the principle expressed in the Latin phrase pacta sunt servanda, which is usually translated "agreements must be kept" but more literally means "pacts must be kept". Contract law can be classified, as is habitual in civil law systems, as part of a general law of obligations, along with tort, unjust enrichment, and restitution. The common law of contract originated with the writ of assumpsit, which was originally a tort action based on reliance.*

*Jurisdictions vary in their principles of freedom of contract. In common law jurisdictions such as England and Wales and the United States, a high degree of freedom is expected. For example, in American law, it was determined in the 1901 case of Hurley v. Eddingfield that a physician was permitted to deny treatment to a patient despite the lack of other available medical assistance and the patient's subsequent death. This is in contrast to the civil law, which typically applies certain overarching principles to disputes arising out of contract, as in the French Civil Code. Other legal systems such as Islamic law, socialist legal systems, and customary law have their own variations.*

*However, in the case of the United States the principle of freedom of contract has eroded over time due to judicial deference to legislation affecting contracts. For example, the Civil Rights Act of 1964 restricted private racial discrimination against African-Americans. In the early 20th century the United States underwent the "Lochner era", in which the Supreme Court of the United States struck down economic regulations on the basis of freedom of contract and the Due Process Clause; these decisions were eventually overturned and the Supreme Court established deference to legislative statutes and regulations which restrict freedom of contract. The U.S. Constitution contains a Contract Clause, but this has been interpreted as only restricting the retroactive impairment of contracts.*

*Not all agreements are necessarily contractual, as the parties generally must have an intention to be legally bound (or the functional equivalent under the objective theory of contracts). In American English, a gentlemen's agreement is one which is not intended to be legally enforceable; the equivalent concept can be expressed an agreement "binding in honor only."*